# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស(អបជ ) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-July-2018, 15:31
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អ.ប.ជ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ
## (សំអាងហេតុ)

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ:**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ:**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
**ទាំងអស់នៃសំណុំរឿង០០៤/១**

**សហមេធាវី អ៊ឹម ចែម:**

ប៊ិត ស៊ាងលឹម

Wayne JORDASH

# I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៦៧(៥) និង ៧៤(២) នៃវិធានផ្ទៃក្នុង[1] សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") ប្ដឹងឧទ្ធរណ៍ "ដីកាដំណោះស្រាយ (សំអាងហេតុ)" របស់សហចៅក្រមស៊ើបអង្កេត ("សចស") ដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេត បានរកឃើញថា អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃច្បាប់ អ.វ.ត.ក ឡើយ[2]។ បណ្ដឹងឧទ្ធរណ៍នេះលើកឡើងទទ្បីករណ៍ចំនួនប្រាំមួយ នៃបណ្ដឹងឧទ្ធរណ៍ដែលពាក់ព័ន្ធទៅនឹងកំហុសអង្គច្បាប់ និងអង្គហេតុរបស់ សចស ក្នុងការវិភាគដែលមាននៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន។

2. ជាទូទៅ ទទ្បីករណ៍នៃបណ្ដឹងឧទ្ធរណ៍នេះទាក់ទងនឹង (i) ការខកខានរបស់ សចស ក្នុងការពិចារណាលើរាល់អង្គហេតុទាំងអស់ ដែលខ្លួនត្រូវបានប្ដឹងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សម្រាប់រឿងក្ដី អ៊ឹម ចែម និងរបៀបដែលអង្គហេតុទាំងអស់នេះអាចប៉ះពាល់លើបញ្ហាថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬយ៉ាងណា។ (ii) កំហុសក្នុងរបៀបដែល សចស វិភាគ និងអនុវត្តធាតុផ្សំនៃឧក្រិដ្ឋកម្មសម្លាប់រង្គាល និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និង (iii) កំហុសក្នុងការរកឃើញនានាអំពីមុខតំណែងរបស់ អ៊ឹម ចែម នៅថ្នាក់ស្រុក និងថ្នាក់តំបន់ ក្នុងតំបន់ ១៣។

3. បណ្ដឹងឧទ្ធរណ៍នេះស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ("អបជ") ធ្វើការកែតម្រូវកំហុសអង្គច្បាប់ និងអង្គហេតុទាំងនេះ និងបញ្ជូនសំណុំរឿងត្រឡប់ទៅ សចស វិញ ដោយណែនាំឱ្យ សចស ធ្វើការវាយតម្លៃឡើងវិញ ថាតើ អ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ឬយ៉ាងណា ឬជាជម្រើសម្យ៉ាងទៀត សុំឱ្យ អបជ ធ្វើការវាយតម្លៃរឿងក្ដីនេះឡើងវិញដោយខ្លួនឯង ដោយពិចារណាលើរាល់អង្គហេតុទាំងអស់មកពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ សហព្រះរាជអាជ្ញា អំពីកម្រិតពិតប្រាកដនៃមុខតំណែងសិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និងអនុវត្តឱ្យបានត្រឹមត្រូវនូវនិយមន័យនៃការសម្លាប់រង្គាល និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ។

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានកែប្រែឡើងវិញនៅថ្ងៃទី១៦ ខែ១៦ ខែមករា ឆ្នាំ២០១៥។

[2] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧។

## II. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣ ដោយបានស្នើឲ្យស៊ើបសួរទាក់ទងនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម និងបុគ្គលបីនាក់ផ្សេងទៀត[3]។ ជាបន្តបន្ទាប់ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំនួនបួន[4]។

5. នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ សចស បានស្នើឲ្យភាគីដាក់សារណាអំពី ថាតើ អ៊ឹម ចែម គួរតែពិចារណាថាជា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ឬ ជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[5] ដែរឬទេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ប៉ុន្តែគាត់ជាជនម្នាក់ក្នុងចំណោម ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[6]។

6. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សចស បានដាក់សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម[7] និងសេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម

---

3 **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨។

4 **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ១៨ កក្កដា ២០១១។ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ, ២៤ មេសា ២០១៤។ **D254/1** ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តអង្គតាមាក់, ៤ សីហា ២០១៥។ **D272/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤, ២០ វិច្ឆិកា ២០១៥។

5 **D251** សំណើសុំដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" និង/ឬ ស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែរឬទេ, ២៤ កក្កដា ២០១៥។

6 **D251/5** សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ២១ កញ្ញា ២០១៥, កថាខណ្ឌ៤៤, ៤៥, ៥១។

7 **D285** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម, ១៨ ធ្នូ ២០១៥។

និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់[8]។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ សចស បានចេញដីកាបញ្ជូនរឿងទៅពិនិត្យ[9]។ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនប្រឆាំង អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ដោយសន្និដ្ឋានថា អ៊ឹម ចែម គួរតែត្រូវបានបញ្ជូនទៅជំនុំជម្រះ[10]។

7. នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ សចស បានចេញដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ដោយច្រានចោលបទចោទប្រឆាំង អ៊ឹម ចែម[11]។ នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាបានដាក់សំណើសុំរបស់ខ្លួន ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង០០៤/០១ ក្រោយការផ្តល់សំអាងហេតុពេញលេញរបស់សហចៅក្រមស៊ើបអង្កេត[12] ដោយសន្និដ្ឋានថា គាត់មិនអាចធ្វើសេចក្តីសម្រេចចិត្តប្រកបដោយជ្រួតជ្រាបសម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់បានឡើយ បើមិនបានដឹងសំអាងហេតុពេញលេញសម្រាប់ការលើកលែងការចោទប្រកាន់។ អង្គបុរេជំនុំជម្រះបានផ្តល់ការអនុញ្ញាតតាមសំណើសុំនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៦[13]។

8. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សចស បានចេញដីកាដំណោះស្រាយ (សំអាងហេតុ)[14]។ នៅថ្ងៃដដែលនេះដែរ សចស បានចេញដីកាសម្រេចរបស់ខ្លួនលើសំណើរបស់សហព្រះរាជអាជ្ញា

---

8 **D286** សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់, ១៨ ធ្នូ ២០១៥។

9 **D304** ដីកាបញ្ជូនរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤), ២៧ កក្កដា ២០១៦។

10 **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម, ២៧ តុលា ២០១៦ ("ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦")។

11 **D308** ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី), ២២ កុម្ភៈ ២០១៧។

12 **D308/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/១ ក្រោយការផ្តល់សំអាងហេតុពេញលេញរបស់សហចៅក្រមស៊ើបអង្កេត, ២ មីនា ២០១៧។

13 **D308/2** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/១ ក្រោយការផ្តល់សំអាងហេតុពេញលេញរបស់សហចៅក្រមស៊ើបអង្កេត, ៦ មីនា ២០១៧។

14 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧។

សុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ[15] និង បានដាក់សំណៅកោសល្យុបដ៏ច្រើននៃដីកាដំណោះស្រាយ (សំអាងហេតុ)។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញា បានដាក់ សៀវភៅចុះបណ្តឹងឧទ្ធរណ៍នៃសេចក្តីជូនដំណឹងរបស់ខ្លួន អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ សចស (សម្អាងហេតុ)[16]

## III. ច្បាប់ជាធរមាន

9. តាមវិធាន ៦៧ - នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន សចស -"ធ្វើការសម្រេចចុងក្រោយពាក់ព័ន្ធនឹងការកំណត់បទចោទនៃអំពើនានាដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងសម្រេចលើបញ្ហាថាតើអំពើទាំងនោះចាត់ទុកជាបទឧក្រិដ្ឋនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ"[17]។ អនុលោមតាមវិធាន ៦៧(៥) ដីកាដំណោះស្រាយជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ដោយសហព្រះរាជអាជ្ញា ដូចមានចែងកំណត់នៅក្នុងវិធាន ៧៤ - ដែលគ្រប់គ្រងទៅលើ "ទទ្បីករណ៍នៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ"។ វិធាន ៧៤(២) ចែងថា សហព្រះរាជអាជ្ញា "អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត"។

10. អង្គបុរេជំនុំជម្រះបានរកឃើញថា គេបានបង្ហាញនៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិថា ចំពោះបណ្តឹងឧទ្ធរណ៍ "ការភ័ន្តច្រឡំអង្គច្បាប់ ដែលបានលើកឡើងត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីកំណត់ថាតើ សេចក្តីសម្រេចផ្លូវច្បាប់ មានលក្ខណៈត្រឹមត្រូវដែរឬទេ និងការភ័ន្តច្រឡំអង្គហេតុដែលបានលើកឡើងត្រូវបានពិនិត្យមើល ស្របតាមបទដ្ឋានស្តីពីភាពសមហេតុសមផលដើម្បីកំណត់ថា តើពុំមានអ្នកវិនិច្ឆ័យអង្គហេតុដ៏មានហេតុផល អាចឈានទៅដល់ការរកឃើញអង្គហេតុដែលបានលើកឡើងនេះ ដែរឬទេ"[18]។

---

[15] **D309/2** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ, ១០ កក្កដា ២០១៧។

[16] **D308/3/1** សៀវភៅចុះបណ្តឹងឧទ្ធរណ៍នៃសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ), ២០ កក្កដា ២០១៧។

[17] **D427/3/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, កថាខណ្ឌ ៧៩។

[18] **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ១១ មេសា ២០១១, កថាខណ្ឌ១១៣។

## IV. សេចក្តីសន្និដ្ឋានចំពោះការដាក់បណ្តឹងឧទ្ធរណ៍

### ទឡ្ហីករណ៍ទី១: សចស មានកំហុសអង្គច្បាប់ដែលរកឃើញថា ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ត្រូវតែចោទដើម្បីបានជាផ្នែកនៃដីកាដំណោះស្រាយ

11. នៅក្រោមច្បាប់ អ.វ.ត.ក និងច្បាប់កម្ពុជា ចៅក្រមស៊ើបសួរត្រូវបានប្តឹង *ទល់នឹងវត្ថុ* ចំពោះការចោទប្រកាន់ផ្នែកអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់អយ្យការ។ ពួកគាត់មានកាតព្វកិច្ចដើម្បីស៊ើបអង្កេតទៅលើអង្គហេតុទាំងអស់នេះដើម្បីពិចារណាឲ្យដឹងថា តើភស្តុតាងទាំងនោះកំណត់បានថាបុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានទាំងនោះ មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មណាមួយនៅក្រោមទម្រង់នៃការទទួលខុសត្រូវជាធរមានណាមួយដែរឬទេ។

12. យ៉ាងណាមិញ នៅក្នុងសំអាងហេតុរបស់ពួកគាត់សម្រាប់ដីកាដំណោះស្រាយសម្រាប់ អ៊ឹម ចែម សចស ខកខានមិនបានពិចារណាអំពីការចោទប្រកាន់ផ្នែកអង្គហេតុដែលពួកគាត់ត្រូវបានប្តឹងទេ ឬអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ ដែលបង្ហាញពីរបៀបដែលភស្តុតាងទាំងនោះ គាំទ្រចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដ៏សែនធ្ងន់ធ្ងរជាច្រើនទាំងនោះ។ ការលើកឡើងរបស់ សចស ដែលថា ពួកគាត់មិនចាំបាច់ត្រូវផ្តល់សេចក្តីសម្រេចដែលមានសំអាងហេតុ ថាតើភស្តុតាងនោះកំណត់បានអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះឡើយដោយសារ សចស ខ្លួនឯងផ្ទាល់មិនបាន "ចោទ" អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ ឬទម្រង់នៃការទទួលខុសត្រូវទាំងនោះ។ ពួកគាត់ពន្យល់ការផ្តល់សំអាងហេតុរបស់ខ្លួន ដូចខាងក្រោម៖

> អ៊ឹម ចែម ត្រូវបានចោទប្រកាន់ចំពោះតែឧក្រិដ្ឋកម្មមួយចំនួនដែល សពអ ចោទប្រកាន់ថា គាត់ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ពោលគឺ ការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ូង និងការដ្ឋានទំនប់ស្ពានស្រែង ប៉ុណ្ណោះ។
>
> ទោះបីជាយ៉ាងនេះក្តី សពអ ស្នើសុំឲ្យ សចស ចោទប្រកាន់បញ្ជូន អ៊ឹម ចែម ទៅជំនុំជម្រះលើបទឧក្រិដ្ឋដែលមានលក្ខណៈទូលាយជាងនេះ ដែលបានប្រព្រឹត្តតាមរយៈ

ទម្រង់នៃការទទួលខុសត្រូវច្រើនជាងនេះ លើសពីបទឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់លើរូបគាត់។ មេធាវីការពារក្ដីបានជំទាស់យ៉ាងត្រឹមត្រូវថា ការចោទប្រកាន់បែបនេះមិនអនុញ្ញាតនោះទេ។ គោលការណ៍ជាមូលដ្ឋាននៃដំណើរការត្រឹមត្រូវ គឺការជូនដំណឹងលម្អិតអំពីចរិកលក្ខណៈ និងមូលហេតុនៃបទចោទ ហើយគោលការណ៍នេះ គឺជាលក្ខខណ្ឌចាំបាច់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការរៀបចំការការពារក្ដីរបស់ខ្លួន។ ជនត្រូវចោទអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះតែបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់ និងជូនដំណឹងត្រឹមត្រូវប៉ុណ្ណោះ[19]។

13. ការផ្ដល់សំអាងហេតុដោយ សចស មានកំហុសសម្រាប់មូលហេតុជាច្រើន។ ទីមួយ មេធាវីការពារក្ដី ត្រូវបានជូនដំណឹងចំពោះអង្គហេតុទាំងឡាយដែលអាចនាំទៅដល់ការចោទប្រកាន់ តាមរយៈសិទ្ធិចូលពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ នៅក្រោមប្រព័ន្ធចៅក្រមស៊ើបសួរ/ប្រព័ន្ធច្បាប់ស៊ីវិល ដូចនៅ អ.វ.ត.ក នេះ មេធាវីការពារក្ដីយល់ថា សចស មានកាតព្វកិច្ចដើម្បីស៊ើបអង្កេតគ្រប់អង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងនេះ។

14. ការដាក់ឯកសាររបស់ អ៊ឹម ចែម ខ្លួនឯងផ្ទាល់នៅក្នុងរយៈពេលនៃដំណើរការស៊ើបអង្កេត បង្ហាញឲ្យឃើញថា គាត់មិនត្រឹមតែបានយល់ថាអង្គហេតុដែលមិនត្រូវបាន "ចោទប្រកាន់" ដោយ សចស អាចត្រូវបានស៊ើបសួរ ហើយជាចុងក្រោយអាចនាំទៅដល់ការចោទប្រកាន់ប៉ុណ្ណោះទេ គាត់ថែមទាំងបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួនទៀតផង ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលគាត់មិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ។ នៅក្រោយការចេញឯកសារចោទប្រកាន់ *ដោយកំបាំងមុខ* ដំបូង - អ៊ឹម ចែម បានស្នើឲ្យ កសចស ដាក់ប្រតិចារឹកសវនាការពីសំណុំរឿង ០០២/០២ ទៅក្នុងសំណុំរឿងរបស់គាត់ "ដោយសារលោកស្រី អ៊ឹម ចែម ក៏ត្រូវបាននិងកំពុងស៊ើបសួរចំពោះទំនប់អាងត្រពាំងថ្ម ដែរ"[20] - ទោះបីជា ទំនប់អាងត្រពាំងថ្ម មិនត្រូវបានរៀបរាប់នៅក្នុងឯកសារចោទប្រកាន់*ដោយកំបាំងមុខ* ក៏ដោយ។ ដូចបានទទួលស្គាល់ដោយ អ៊ឹម ចែម សំណើសុំ

[19] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៤៤-២៤៥។

[20] **D283** សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យដាក់បង្ហាញរាល់ប្រតិចារឹកនៃសំណុំរឿង០០២ ដែលមិនមែនជាសំណៅកោសលុប ព្រមទាំងឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនឹងអ្នកស្រី, ១៥ ធ្នូ ២០១៥, កថាខណ្ឌ ២ ("សំណើរបស់ អ៊ឹម ចែម សុំប្រតិចារឹកសំណុំរឿង ០០២")។

ដាក់សក្ខីកម្មសវនាការទាក់ទងនឹងទំនប់អាងត្រពាំងថ្មទៅក្នុងសំណុំរឿង០០៤/០១ ត្រូវបានធ្វើឡើង "ដើម្បីការពារសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌របស់ អ៊ឹម ចែម ដើម្បីជួយសម្រួលដល់ការរៀបចំការការពារក្តីរបស់គាត់ឲ្យបានគ្រប់គ្រាន់និងដើម្បីដេញដោលសាក្សីដែលប្រឆាំងនឹងគាត់"[21] ។ អ៊ឹម ចែម បានគាំទ្រចំពោះសំណើនេះតាមរយៈការដកស្រង់មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ថា "ជនត្រូវចោទមានសិទ្ធិ [...] ដើម្បីសួរដេញដោលលើភ័ស្តុតាងដែលប្រឆាំងនឹងពួកគេ"[22]។ ប្រសិនបើ អ៊ឹម ចែម ពិចារណាថា ការចោទប្រកាន់ទាំងនេះទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនេះ លើសពីវិសាលភាពដែលអាចអនុញ្ញាតបានចំពោះលទ្ធភាពនៃការចោទប្រកាន់ ម្ល៉េះការស្នើសុំឲ្យដាក់ភ័ស្តុតាងនេះទៅក្នុងសំណុំរឿងមិនចាំបាច់ឡើយ។ លើសពីនេះ សចស បានផ្តល់តាមសំណើទាំងនេះ[23] ដោយបានបង្ហាញថា ពួកគាត់ក៏បានយល់ផងដែរថា អង្គហេតុទាំងឡាយដែលមិនទាន់បានបញ្ចូលទៅក្នុង "បទចោទ" ដែលគាត់បានជូនដំណឹងដល់ អ៊ឹម ចែម រួចហើយនោះ ក៏នៅតែពាក់ព័ន្ធ ដោយសារថាវាអាចនាំទៅដល់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ។

15. ទីពីរ គោលជំហររបស់ សចស បដិសេធដាច់អហង្ការចំពោះសិទ្ធិរបស់សហព្រះរាជអាជ្ញាដើម្បីធ្វើសវនាការលើភ័ស្តុតាងស្តីពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម សម្រាប់ឧក្រិដ្ឋកម្មទាំងនេះ។ វិធានផ្ទៃក្នុង មិនផ្តល់ឱកាសណាមួយដល់សហព្រះរាជអាជ្ញាដើម្បីធ្វើសវនាការថាតើឧក្រិដ្ឋកម្មណាមួយដែល សចស នឹងបញ្ចូលទៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទរបស់ពួកគេ អនុលោមតាមវិធាន ៥៧នៃវិធានផ្ទៃក្នុងទេ។ ក្នុងករណីនេះវិញ សហព្រះរាជអាជ្ញាមិនត្រូវបានអញ្ជើញឲ្យដាក់សារណាអំពីថាតើមានឧក្រិដ្ឋកម្មណាខ្លះដែល អ៊ឹម ចែម ត្រូវបានចោទប្រកាន់នោះទេ ហើយក៏មិនត្រូវបានអញ្ជើញឲ្យចូលរួមស្តាប់សវនាការពេលគាត់ត្រូវបានជូនដំណឹងអំពីបទចោទដែរ។ គោលការណ៍ជាមូលដ្ឋាននៃដំណើរការត្រឹមត្រូវមួយ គឺការផ្តល់ឲ្យភាគីទាំងអស់នូវឱកាសដើម្បី បានធ្វើសវនាការ[24]។ ប្រសិនបើអំណះអំណាងនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹង

---

21 **D283** សំណើរបស់ អ៊ឹម ចែម សុំប្រតិចារឹកសំណុំរឿង ០០២, កថាខណ្ឌ ៣។

22 **D283** សំណើរបស់ អ៊ឹម ចែម សុំប្រតិចារឹកសំណុំរឿង ០០២, កថាខណ្ឌ ១០។

23 **D289** ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំដាក់បង្ហាញសំណៅគ្មានការកោសលុបនៃប្រតិចារឹកសំណុំរឿង ០០២ និងឯកសារពាក់ព័ន្ធនឹងគាត់ និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម, ១១ មករា ២០១៦។

24 *សូមមើល,* **D121/4/1/4** ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត, ១៥ មករា ២០១៤។

អង្គហេតុដែលមិនត្រូវបានចោទប្រកាន់ត្រូវបានគេធ្វើមិនដឹងមិនឮ ជាលទ្ធផលវានឹងក្លាយជាអង្គហេតុដែលត្រូវបានច្រានចោលដោយគ្មានសេចក្តីសម្រេចដែលមានសំអាងហេតុ និងដោយគ្មានការផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាបានធ្វើសវនាការជាមួយ សចស។

16. ទីបី គោលជំហររបស់ សចស នឹងបដិសេធសិទ្ធិប្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងការរកឃើញរបស់ សចស ដោយហេតុថាភស្តុតាងនៅលើអង្គហេតុដែល សចស ត្រូវបានប្តឹងនោះមិនត្រូវបានចោទប្រកាន់។ សចស មិនបានចេញដីកាសម្រេចមុនការចោទប្រកាន់ អ៊ឹម ចែម ចំពោះការចោទប្រកាន់មួយចំនួន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាទេ ហើយចៅក្រម Harmon ក៏បានជូនដំណឹងយ៉ាងជាក់ច្បាស់ដល់ អ៊ឹម ចែម ថាគាត់អាចនឹងត្រូវបានចោទប្រកាន់នៅពេលក្រោយចំពោះឧក្រិដ្ឋកម្មបន្ថែមទៀត[25]។ ដូច្នេះ គ្មាន "សេចក្តីសម្រេច" ណាមួយសម្រាប់សហព្រះរាជអាជ្ញា ដើម្បីប្តឹងឧទ្ធរណ៍ក្នុងពេលណាមួយនៅក្នុងអំឡុងនៃកិច្ចស៊ើបសួរឡើយ។ បើដីកាដំណោះស្រាយមិនបានដោះស្រាយចំពោះអង្គហេតុនានាដែលបានប្តឹងទៅ សចស ប៉ុន្តែដោយពួកគាត់មិនបានចោទប្រកាន់ជនសង្ស័យ នោះសហព្រះរាជអាជ្ញាត្រូវបានបដិសេធសិទ្ធិប្តឹងឧទ្ធរណ៍ទៅ អបជ ចំពោះសំអាងហេតុនៃសេចក្តីសម្រេចណាមួយដែលមិនចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវជាក់លាក់នោះ។

---

យោបល់របស់ចៅក្រម Chang-Ho Chung និង Rowan Downing, កថាខណ្ឌ៩, *បានយោងសំអាងដោយការអនុញ្ញាតជាអាទិ៍* សំណុំរឿង០០២- **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣, កថាខណ្ឌ ៤២ ("ភាពចាំបាច់ក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ [...] ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងជាផលប្រយោជន៍យុត្តិធម៌ដ៏មានអត្ថន័យ និងស្របទៅតាមបទដ្ឋានគតិយុត្តអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែល")។ តុលាការយុត្តិធម៌អន្តរជាតិ, រឿងក្តី អូស្ត្រាលី ទល់នឹង បារាំង, សាលក្រម (រឿងក្តីសាកល្បងនុយក្លេអ៊ែ- យោបល់ជំទាស់របស់ចៅក្រម Sir Garfield Barwick), ២០ ធ្នូ ១៩៧៤, ទំព័រ៣៩១ ("ក្នុងករណីណាក៏ដោយ អ្នកដាក់ពាក្យសុំត្រូវតែមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានចំពោះរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធក្នុងសេចក្តីសម្រេចរបស់តុលាការ")។ ECtHR, រឿងក្តី Niderost-Huber ទល់នឹង Switzerland, បណ្តឹងលេខ 18990/91, សាលក្រម, ១៨ កុម្ភៈ ១៩៩៧, កថាខណ្ឌ ២៩ (បានសង្កត់ធ្ងន់ថា ទំនុកចិត្តរបស់ "គូក្តី"ក្នុងកិច្ចការយុត្តិធម៌ [...]ត្រូវផ្អែកលើ ជាអាទិ៍ ចំណេះដឹងដែលថាពួកគេមានឱកាសបញ្ចេញទស្សនៈរបស់ខ្លួនលើរាល់ឯកសារនៅក្នុងសំណុំរឿង)។

25 **D239.1** សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥, កថាខណ្ឌ ១៩។

17. អង្គហេតុដែល សចស មិនអាចចេះតែទម្លាក់ចោលការស៊ើបអង្កេតលើអង្គហេតុនានា ដែលពួកគេត្រូវបានប្តឹង ដោយមិនមានការសុំយោបល់ពីសហព្រះរាជអាជ្ញា និងដោយគ្មានដីកាសម្រេចមានសំអាងហេតុនោះ ត្រូវបានបញ្ជាក់បន្ថែមទៀតដោយវិធាននផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្មថ្មីបំផុត។ វិធាន ៦៦(ស្ទួន) នៃវិធាននផ្ទៃក្នុងផ្តល់មធ្យោបាយឲ្យសហចៅក្រមស៊ើបអង្កេតកែសម្រួលការស៊ើបអង្កេត និងបន្ថយវិសាលភាពនៃការស៊ើបអង្កេតដោយដកចេះនូវអង្គហេតុខ្លះ ដែលមានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម ឬបន្ថែម របស់សហព្រះរាជអាជ្ញា ប្រសិនបើអង្គហេតុដែលនៅសេសសល់ទាំងនោះត្រូវបានតំណាងហើយនោះ។ ទោះជាយ៉ាងណាវិធាននេះតម្រូវឲ្យ សចស រង់ចាំរហូតដល់ពេលបញ្ចប់កិច្ចស៊ើបសួរ និងត្រូវជូនដំណឹងដល់សហព្រះរាជអាជ្ញា និងភាគីផ្សេងទៀត អំពីចេតនារបស់ខ្លួនក្នុងការប្រើប្រាស់វិធាននេះដើម្បីកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតនោះ។ ពួកគេត្រូវតែអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និងភាគីផ្សេងទៀតនូវឱកាសមួយដើម្បីធ្វើសេចក្តីសន្និដ្ឋានលើការកាត់បន្ថយដែលស្នើឡើងនោះ។ ដីកាសម្រេចណាមួយដកចេញនូវអង្គហេតុនានាតាមវិធាន ៦៦ស្ទួន នៃវិធាននផ្ទៃក្នុងត្រូវស្ថិតក្រោមការប្តឹងឧទ្ធរណ៍ ដែលបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាវាត្រូវតែជាដីកាសម្រេចដែលមានសំអាងហេតុ។ មិនចាំបាច់មានវិធាន ៦៦*ស្ទួន* នៃវិធាននផ្ទៃក្នុងនោះឡើយ ប្រសិនបើ សចស ចេះតែអាចមើលរំលងអង្គហេតុមួយណាដែលពួកគេខ្លួនឯងមិនបានចោទប្រកាន់ ដោយមិនផ្តល់ឱកាសឲ្យភាគីនានាផ្តល់យោបល់ និងដោយគ្មានដីកាសម្រេចណាមួយនោះ។

18. ទីបួន ការពឹងផ្អែករបស់ សចស លើដីកាសម្រេចមួយ ដែលបានចេញដោយការិយាល័យរបស់ខ្លួនក្នុងអំឡុងពេលនៃការស៊ើបអង្កេតក្នុងសំណុំរឿង០០២ នោះគឺមិនមានភាពគួរឲ្យជឿជាក់នោះឡើយ។ សចស ខកខានមិនបានបកស្រាយដីកាសម្រេចនោះទាំងមូលនោះឡើយ។ សចស ពឹងផ្អែកលើប្រយោគតែមួយគត់ពីដីការសម្រេចមុនដែលថ្លែងថាៈ "សហចៅក្រមស៊ើបអង្កេតមិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះ ចំពោះអង្គហេតុណាដែលបុគ្គលនោះមិនត្រូវបានចោទប្រកាន់"[26]។

19. ប៉ុន្តែ ប្រយោគយ៉ាងជិតបន្តពីក្រោយមានសារសំខាន់ក្នុងការបកស្រាយដីកាសម្រេចនោះទាំងមូល និងពិតជាផ្ទុយទាំងស្រុងទៅនឹងការលើកឡើងរបស់ សចស ដែលថាដីកាដំណោះស្រាយអាច

---

[26] សំណុំរឿង០០២-**D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ, ២០ វិច្ឆិកា ២០០៩, កថាខណ្ឌ១០។

រំលងចោលអង្គហេតុនានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម និងបន្ថែម គ្រាន់តែដោយសារពួកវាមិនបាន "ចោទប្រកាន់" ជនសង្ស័យអំពីឧក្រិដ្ឋកម្មជាក់លាក់ទាំងអស់នេះ ឬអំពីទម្រង់នៃការទទួលខុសត្រូវ។ វាលើកឡើងថា "<u>នៅក្នុងដីកាដំណោះស្រាយ</u> សហចៅក្រមស៊ើបអង្កេត<u>ត្រូវវិនិច្ឆ័យលើ អង្គហេតុទាំងអស់ដែលត្រូវបានប្ដឹងដោយត្រឹមត្រូវតាមនីតិវិធីច្បាប់</u>។ ក្នុងនោះសហចៅក្រមស៊ើបអង្កេតអាចនឹងចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់"[27]។ ការសម្រេចនេះផ្អែកលើយុត្តិសាស្ត្រច្បាប់ស៊ីវិល ដែលចែងអំពីអត្ថិភាពនៃកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើការរកឃើញកំណត់ចុងក្រោយនៅក្នុងដីកាដំណោះស្រាយ លើរាល់ការចោទប្រកាន់ទាំងអស់ដែលត្រូវបានប្ដឹងទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើការស៊ើបអង្កេត[28]។ "កាតព្វកិច្ច" នេះនឹងបញ្ចប់ប្រសិនបើ សចស អាចគ្រាន់តែបញ្ជូនទៅជំនុំជម្រះផ្អែកលើអង្គហេតុដែល*ពួកគេបានចោទប្រកាន់*ដែលផ្ទុយទៅនឹងអង្គហេតុនានាដែល*ពួកគេត្រូវបានប្ដឹង*នោះ។

20. ដីកាសម្រេចក្នុងសំណុំរឿង០០២ ដែល សចស បានផ្អែកលើនោះ យោងសំអាងឧទាហរណ៍ពីរនៃច្បាប់បារាំង ដើម្បីគាំទ្រការលើកឡើងរបស់ខ្លួនលើការបញ្ជូនទៅជំនុំជម្រះដោយមិនមានការចោទប្រកាន់។ យោងសំអាងទីមួយប្រកាសថា៖

> *Nul ne pouvant être jugé, ni mis en accusation sans avoir été entendu ou dûment appelé, une instruction ne doit pas être close et la mise en accusation prononcée contre un inculpé, même arrêté postérieurement à la date de l'ordonnance de transmission de pièces au Procureur général, sans qu'il ait été mis en mesure de répondre aux inculpations et de produire ses justifications.*[29]

---

27 សំណុំរឿង០០២-**D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ, កថាខណ្ឌ១០ (គូសបញ្ជាក់បន្ថែម)។

28 *សូមមើល ឧ.* Crim 24 mars 1977 Bull crim N°112, « *Le juge d'instruction est tenu d'informer sur tous les faits dont il a été régulièrement saisi* »; See also: « *Le juge est tenu de statuer par ordonnance du règlement sur tous les faits dont il a été régulièrement saisi* ».

29 Crim 12 octobre 1972, *Bull crim* no 286 ("ដោយសារគ្មានបុគ្គលណាត្រូវបានវិនិច្ឆ័យ ឬបញ្ជូនទៅជំនុំជម្រះដោយគ្មានការស្ដាប់សវនាការ ឬកោះហៅនោះ ដូច្នេះការស៊ើបអង្កេតមិនអាចបិទនោះទេ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញប្រឆាំងនឹងជនត្រូវចោទនោះ ទោះបីជាគាត់ត្រូវបានចាប់ខ្លួនក្រោយថ្ងៃបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញាក៏ដោយ ប្រសិនបើរូបគាត់មិនត្រូវបានដាក់ក្នុងជំហរមួយដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនោះ និងធ្វើការការពារខ្លួនរបស់គាត់នោះ។") (បកប្រែក្រៅផ្លូវការដោយ កសព) *យោងសំអាងក្នុង* សំណុំរឿង០០២ -**D198/1** ដីកាសម្រេចលើសំណើសុំការបំភ្លឺអំពីការចោទបក្រាន់, ជើងទំព័រ ១៥។

21. កំណត់សម្គាល់ទីពីរថា៖

*Lorsqu'un inculpé s'est expliqué sur le fond lors de sa première comparution devant le Juge d'instruction il n'est pas fondé à soutenir qu'en l'absence d'interrogatoire ultérieur, il y a eu atteinte aux droits de la défense.*[30]

22. ប្រភពទាំងនេះតំណាងឲ្យការលើកឡើងជាមូលដ្ឋានថា បុគ្គលម្នាក់ត្រូវតែ "ទទួលបានការជូនដំណឹងជាលម្អិតអំពីលក្ខណៈ និងហេតុផលនៃការចោទប្រកាន់" ដែលបានចោទប្រឆាំងនឹងខ្លួន[31]។ នេះគឺជាគោលបំណងតែមួយគត់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមណាមួយជាបន្តបន្ទាប់មកទៀត។ ដីកាសម្រេចក្នុងសំណុំរឿង០០២ ដែលបានផ្អែកលើដោយ សចស គ្រាន់តែបញ្ជាក់ឡើងវិញអំពីភាពអាចអនុវត្តបាននៅ អ.វ.ត.ក នៃការអនុវត្តច្បាប់ស៊ីវិល ដែលបុគ្គលម្នាក់មិនអាចត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះការចោទប្រកាន់អង្គហេតុនោះទេ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងដោយត្រឹមត្រូវតាមច្បាប់អំពីអង្គហេតុទាំងនោះតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម និងបន្ថែមនោះ[32]។

---

30 Crim 6 novembre *1979, Bull crim* no 306 ("នៅពេលដែលជនត្រូវចោទបានផ្តល់ការពន្យល់របស់ខ្លួនលើអង្គសេចក្តីក្នុងអំឡុងពេលការបង្ហាញខ្លួនលើកដំបូងរបស់គាត់នៅចំពោះមុខចៅក្រមស៊ើបអង្កេតនោះ រូបគាត់មិនត្រូវបានអនុញ្ញាតដោយច្បាប់ឲ្យនិយាយដោយមិនមានការសួរចម្លើយបន្ទាប់ក្រោយមកទៀតនោះទេ គឺសិទ្ធិការពារខ្លួនរបស់គាត់នឹងត្រូវបានរំលោភ") (បកប្រែក្រៅផ្លូវការដោយ កសព) *យោងសំអាងក្នុង* **D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ, ជើងទំព័រ ១៥។

31 *សូមមើល*, **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៩៥។

32 សូមមើល *ឧ.*, ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, មាត្រា ៨០៖ "នៅពេលដែលបទល្មើសដែលមិនមាននៅក្នុង ដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវបានបញ្ជូនទៅឲ្យចៅក្រមស៊ើបអង្កេតពិចារណា គាត់ត្រូវតែទំនាក់ទំនងភ្លាមទៅកាន់ព្រះរាជអាជ្ញាប្រចាំតំបន់ អំពីបណ្តឹង ឬកំណត់ត្រាផ្លូវការដែលបង្ហាញពីអត្ថិភាពរបស់វា។ បន្ទាប់មកព្រះរាជអាជ្ញាប្រចាំតំបន់អាចស្នើសុំតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ឲ្យចៅក្រមស៊ើបអង្កេតស៊ើបអង្កេតលើអង្គហេតុបន្ថែមទៀត ឬ តម្រូវឲ្យមានការបើកការស៊ើបអង្កេតដាច់ដោយឡែក ឬបញ្ជូនសំណុំរឿងទៅតុលាការជំនុំជម្រះ ឬបង្គាប់ឲ្យមានការសាកសួរ ឬសម្រេចទម្លាក់ចោលសំណុំរឿងនោះ ឬបន្តទៅវិធានការមួយក្នុងចំណោមវិធានការនានាដែលផ្តល់ឲ្យក្នុងមាត្រា ៤១-១ ដល់ ៤១-៣ ឬត្រូវផ្ទេរបណ្តឹងនោះ ឬកំណត់ត្រាផ្លូវការទាំងនោះទៅព្រះរាជអាជ្ញាប្រចាំតំបន់ដែលមានមត្តកិច្ចដែនដី" និងមាត្រា ១៨១៖ "ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះរួមមាន ស្ថិតក្រោមទណ្ឌកម្មនៃមោឃភាព ការបង្ហាញ និង គុណវុឌ្ឍិច្បាប់នៃបញ្ញានានាដែលការ ចោទប្រកាន់ពាក់ព័ន្ធ និង អត្តសញ្ញាណជាក់លាក់របស់ជនជាប់ចោទ"។

## ចន្លឹករណ៍ទី២÷ សចស មានកំហុសផ្នែកច្បាប់ដោយខកខានមិនបានដោះស្រាយអង្គហេតុដែលបានប្តឹងទៅខ្លួន

23. សចស បានខកខានមិនបានដោះស្រាយការចោទប្រកាន់ជាច្រើនដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ សពអ។ ដីកាដំណោះស្រាយអះអាងថា "បានផ្តល់នូវទិដ្ឋភាពរួមនៃភ័ស្តុតាងពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់៥ ដែល អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់នោះ"[33] និងថ្លែងថា សូម្បីតែបានពិចារណាលើភ័ស្តុតាងទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះក៏ដោយ ក៏វាមិនផ្លាស់ប្តូរយុត្តាធិការបុគ្គលរបស់ពួកគេដែរ[34]។ ប៉ុន្តែ ដីកាដំណោះស្រាយ (សំអាងហេតុ) ខកខានមិនបានដោះស្រាយអង្គហេតុនានាទាក់ទងនឹងឧក្រិដ្ឋកម្មដ៏សំខាន់ៗជាច្រើន ដែលត្រូវបានប្តឹងទៅ សចស នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ សពអ ដែលមិនត្រូវបាន "ចោទប្រកាន់" ដោយ សចស[35]។ ទាំងអស់នេះរួមមាន៖ (i) ការបោសសម្អាតភូមិភាគពាយ័ព្យ (ii) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងតំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់៥ នៃភូមិភាគពាយ័ព្យ (iii) ការធ្វើទុក្ខបុកម្នេញលើជាតិពន្ធុវៀតណាមនៅក្នុងតំបន់៥ (iv) ឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមនៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និង (v) ការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងក្រុមនយោបាយ និងជាតិពន្ធុជាច្រើនទៀត និងការធ្វើទារុណកម្ម ការបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃផ្សេងៗទៀតនៅតាមទីតាំងជាក់លាក់ ដែលពួកវាត្រូវបានប្តឹងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។

### ក. សចស បានខកខានមិនបានពិចារណាភ័ស្តុតាងនៃការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះការបោសសម្អាតនៅភូមិភាគពាយ័ព្យនិងបានអនុវត្តមិនត្រឹមត្រូវអំពីច្បាប់ JCE

---

33 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៤៦។

34 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៤៦។

35 *សូមមើល* **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨។ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ១៨ កក្កដា ២០១១។ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ, ២៤ មេសា ២០១៤។

24. ទោះបីជាមានការរកឃើញដ៏លម្អិតថា អ៊ឹម ចែម បានដឹកនាំ និងបានចូលរួមក្នុងអ្វីដែល សចស រៀបរាប់ថាជា "ការងារសម្របសម្រួលដ៏សំខាន់" ដែលជាការបោសសម្អាតភូមិភាគពាយ័ព្យ[36] នោះក៏ដោយ ក៏ សចស បានខកខានមិនបានពិចារណាលើការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលបណ្តាលមកពីការបោសសម្អាតទាំងនោះ នៅពេលដែលធ្វើការវាយតម្លៃលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ដីកាដំណោះស្រាយនេះមិនមានការពិភាក្សាអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងអស់នេះទេ ដូចជា ការប៉ាន់ប្រមាណចំនួនអ្នកត្រូវបានសម្លាប់ ការប្រើប្រាស់ទារុណកម្ម និងការឈឺចាប់របស់ជនរងគ្រោះ (ឧទាហរណ៍ កូនក្មេងត្រូវបានសម្លាប់ដោយសារគ្រាន់តែជាកូនចៅរបស់អ្នកដែលត្រូវបានគេកំណត់ថាជាខ្មាំងដោយរបបនោះប៉ុណ្ណោះ)។

25. នៅក្នុងដីកាដំណោះស្រាយ សចស បានរកឃើញថា អ៊ឹម ចែម ត្រូវបានជ្រើសរើសដោយ តាម៉ុក[37] ឲ្យដឹកនាំរលកទីពីរនៃកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យក្នុងប្រតិបត្តិការ ឆ្នាំ១៩៧៧ និង ១៩៧៨ ដែលបានរៀបចំឡើងដើម្បីបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ[38]។ សចស បានរកឃើញបន្ថែមទៀតថា "ក្រោយពីការមកដល់នៃកម្មាភិបាលភូមិភាគនិរតី កម្មាភិបាលយោធាភូមិភាគពាយ័ព្យ និងស៊ីវិលនៅភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនានាទៅទូទាំងភូមិភាគពាយ័ព្យ ដើម្បី "កសាង" ឬសម្លាប់ចោល"[39]។ អ៊ឹម ចែម "បានជំនួសអតីតកម្មាភិបាលពាយ័ព្យទាំងនៅថ្នាក់ស្រុក និងថ្នាក់តំបន់" ដែលកម្មាភិបាលទាំងនោះត្រូវបានបោសសម្អាត"[40]។ ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្លែងបន្តទៀតថា៖

> អ៊ឹម ចែម [...] បានដឹកនាំកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ និងនៅពេលនៅទីនោះបានទទួលខុសត្រូវលើការដ្ឋាន និង មន្ទីរសន្តិសុខថ្នាក់តំបន់។ ភ័ស្តុតាង

---

36 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ៣១៦។

37 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ១៥៥។

38 *សូមមើលផងដែរ*, **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ១៥២, "រលកទីពីរនៃគឺនៅក្នុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ នៅពេលដែល តាម៉ុក បញ្ជូនកម្មាភិបាលភូមិភាគនិរតី ជាមួយនឹងគ្រួសាររបស់ពួកគេ ឲ្យទៅចាប់ខ្លួន និងជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ នៅតាមឃុំ សហករណ៍ និងថ្នាក់ស្រុក ហើយត្រូវបានដឹកនាំដោយ អ៊ឹម ចែម"; កថាខណ្ឌ៣១៦, "ពួកយើងបានដឹងអំពីការពិតដែលថា ផ្អែកលើភ័ស្តុតាងដែលយើងមាន [អ៊ឹម ចែម] ត្រូវបានចាត់តាំងឲ្យដឹកនាំកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ ហើយហេតុដូច្នេះមានតួនាទីដែលមិនស្របគ្នាទៅនឹងលេខាស្រុកទូទៅ"។

39 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៥៣-១៥៤។

40 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៥៤។

បង្ហាញថា គាត់បានដឹងអំពីអ្វីដែលបានកើតឡើងនៅទីនោះផ្ទាល់ តាមរយៈប្រភពជាច្រើន ដូចជា របាយការណ៍ ការទៅទស្សនាដោយផ្ទាល់ ការប្រជុំ និងនិរសារ។ ដូច្នេះ យើងជឿជាក់ថា រូបគាត់បានដឹងអំពីអត្ថិភាពនៃការវាយប្រហារនោះ និងថាអំពើរបស់គាត់ជាផ្នែកមួយនៃការវាយប្រហារនោះ[41]។

26. ខណៈដែលមានការរកឃើញថា អ៊ឹម ចែម បានដើរតួនាទីដ៏សំខាន់នៅក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យក៏ដោយ ក៏ សចស បានខកខានមិនបានពិចារណាអំពីការសម្លាប់ដែលជាលទ្ធផលនោះ និងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធ នៅពេលដែលវាយតម្លៃ ថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងចំណោមមន្ត្រីខ្មែរក្រហមទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបនោះឬយ៉ាងណា។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា ផ្តល់ភស្តុតាងអំពីការបោសសម្អាតកម្មាភិបាលរដ្ឋបាលទាំងអស់នៅក្នុងតំបន់នោះ ចាប់ពីថ្នាក់សហករណ៍ ឃុំ និងកងចល័ត ទៅដល់ថ្នាក់ស្រុក និងកម្មាភិបាលថ្នាក់តំបន់[42]។ គ្រាន់តែចំនួននៃកម្មាភិបាលភូមិភាគពាយ័ព្យតែមួយបញ្ជូនទៅមន្ទីរស-២១ មានចំនួនប្រហែល១២០០នាក់ ដែលភាគច្រើនត្រូវបានកត់ត្រាថាបានមកដល់មន្ទីរស-២១ នៅចន្លោះខែមិថុនា ឆ្នាំ១៩៧៧ និង ខែឧសភា ឆ្នាំ១៩៧៨[43]។ ភស្តុតាងបង្ហាញថា កម្មាភិបាលភូមិភាគពាយ័ព្យជាច្រើនផ្សេងទៀតត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅក្នុងភូមិភាគពាយ័ព្យផ្ទាល់តែម្តង[44]។ ប៉ុន្តែ សចស មិនបានរកឃើញទាល់តែសោះអំពីចំនួនអ្នកដែលត្រូវបានសម្លាប់ ឬស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងនោះ និងខកខានមិនបានពិចារណាអំពីការសម្លាប់ទាំងអស់នេះនៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃច្បាប់ អ.វ.ត.ក ឬអត់នោះ។

## ខ. សចស ខកខានមិនបានពិចារណាភស្តុតាងអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ

41 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៨៤។

42 **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាតាមវិធាន ៦៦, កថាខណ្ឌ ១៧៧។

43 **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងប្រឆាំងនឹង អ៊ឹម ចែម, ២៧ តុលា ២០១៦, កថាខណ្ឌ ១៧៧។

44 **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងប្រឆាំងនឹង អ៊ឹម ចែម, ២៧ តុលា ២០១៦, កថាខណ្ឌ ១៧៧។

27. ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញារៀបរាប់លម្អិតអំពីការជាប់ពាក់ព័ន្ធរបស់ អ៊ឹម ចែម នៅក្នុងការប្រព្រឹត្តអំពើអមនុស្សធម៌ដទៃផ្សេងៗទៀតនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[45]។ សហព្រះរាជអាជ្ញាបានបង្ហាញអំពីរបៀបដែល អ៊ឹម ចែម បានអនុវត្តគោលនយោបាយរបស់ បកក អំពីការបង្ខំបុគ្គលនានាឲ្យរៀបអាពាហ៍ពិពាហ៍ នៅក្នុងរយៈពេលនៃការកាន់ដំណែងរបស់គាត់នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[46]។ ជាពិសេស អ៊ឹម ចែម បានបង្ខំស្ត្រីក្មេងៗនៅក្នុងតំបន់ ១៣ ឲ្យរៀបការជាមួយយុទ្ធជនពិការ[47]។ ហើយនៅក្នុងភូមិភាគពាយ័ព្យវិញ អ៊ឹម ចែម បានធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយមានសាក្សី ថង ធឿយ ដែលជាយុវវ័យនៅពេលនោះ និងអ្នកផ្សេងទៀត[48]។ អ៊ឹម ចែម បានបញ្ជាឲ្យអ្នកក្រោមបង្គាប់តាមដានគូស្រករដើម្បីធានាឲ្យបានថាអាពាហ៍ពិពាហ៍ទាំងនោះមានការរួមសង្វាស[49]។ សេចក្តីរាយការណ៍របស់សាក្សីបានបង្ហាញថា ស្ត្រីមួយចំនួនដែលបដិសេធរួមការរួមភេទត្រូវបានសម្លាប់[50]។ កម្មាភិបាលក្រោមបង្គាប់របស់ អ៊ឹម ចែម ក៏បានប្រព្រឹត្តការរៀងអាពាហ៍ពិពាហ៍ដោយបង្ខំនេះដែរ ហើយបញ្ជីឈ្មោះរបស់អ្នកដែលត្រូវបង្ខំឲ្យរៀបការទាំងនោះត្រូវបានបញ្ជូនឡើងទៅថ្នាក់លើ[51]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតមានឡើងនៅតាមទីតាំងឧក្រិដ្ឋកម្មនានា រួមមានស្ពានស្រែង[52] និងការដ្ឋានទំនប់ត្រពាំងថ្ម[53] និងតាមតំបន់ផ្សេងៗទៀត ដែល អ៊ឹម ចែ មានសិទ្ធិអំណាច[54]។

28. សចស បានខកខានមិនបានវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលស្ថិតនៅក្នុងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃផ្សេងៗទៀត។ ដីកាដំណោះស្រាយខកខានមិនបានវាយតម្លៃស្ថានទម្ងន់ធ្ងន់ធ្ងរនៃបទល្មើសនេះ លទ្ធផល

---

45 **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៥៦-៣៥៩។

46 **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញា, កថាខណ្ឌ២-៤, ១០៨, ១៣២, ១៣៤, ៤៧៦, ៤៧៧, ៤៨០។ សូមមើលផងដែរ កថាខណ្ឌ ៥១, ៥៧, ៥៩, ៦១, ៧២, ៩១-៩៤, ៣៥៦-៣៥៩, ៤៥១។

47 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣៤។

48 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៣២។

49 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣២-១៣៣។

50 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៣២។

51 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៣៣។

52 **D304/2 2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៦៩, ៤៧៦។

53 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់ សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៨៨, ៤៧៦។

54 **D304/2** ដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ របស់ សហព្រះរាជអាជ្ញា, កថាខណ្ឌ៤៧៦។

របស់វាលើអ្នកដែលត្រូវបានខ្លាយជាជនរងគ្រោះ និងសង្គមខ្មែរទាំងមូល។ ការចូលរួមចំណែករបស់ អ៊ឹម ចែម ក្នុងយុទ្ធនាការនៃអាពាហ៍ពិពាហ៍ដោយបង្ខំនេះ គួរត្រូវបានពិចារណាថាតើរូបគាត់ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះ ឬអត់ ក្នុងឋានៈជាមន្ត្រីម្នាក់ក្នុងចំណោមជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងឡាយ។

## គ. សចស ខកខានមិនបានពិចារណាលើភស្តុតាងអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម

29. ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា រៀបរាប់លម្អិតអំពីការពាក់ព័ន្ធរបស់ អ៊ឹម ចែម ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរផ្សេងទៀតទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមនៅក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ[55]។

30. ដូចបានរៀបរាប់យ៉ាងលម្អិតដោយសហព្រះរាជអាជ្ញា អ៊ឹម ចែម បានសារភាពអំពីការទទួលបញ្ជាពីថ្នាក់លើឲ្យស្វែងរក និងចាប់ខ្លួន "ភ្នាក់ងារវៀតណាម"[56]។ អ៊ឹម ចែម បានទទួលប្រវត្តិរូបរបស់មនុស្សដែលស្ថិតនៅក្រោមការត្រួតត្រារបស់គាត់ បានផ្តល់បញ្ជាទាក់ទងនឹងជនទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណថាជាវៀតណាម[57] និងបានទទួលស្គាល់ថា "ភ្នាក់ងារវៀតណាមទាំងអស់ត្រូវបានចាប់ខ្លួន"[58]។

31. ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ដាក់បញ្ចូលភស្តុតាងនៃយុទ្ធនាការដែលគេបានរៀបចំឡើងដើម្បីចាប់ខ្លួន ឃុំឃាំង និងសម្លាប់ជនជាតិវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម តាមបណ្តាទីតាំងនានាដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ អ៊ឹម ចែម៖ មន្ទីរសន្តិសុខភ្នំទ្រយ៉ូង[59] ការដ្ឋានជីកប្រឡាយស្ពានស្រែង[60] មន្ទីរសន្តិសុខចំការខ្នុរ[61] ទីតាំងសម្លាប់មនុស្សព្រៃតា

---

55 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៧២-៤៧៥, ៤៨៦-៥០៣។

56 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៨៥។

57 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៨៦។

58 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៨៧។

59 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៧៤។

60 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩២។

61 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៨៩, ៤៧៤។

វុត[62] ការដ្ឋានទំនប់ត្រពាំងថ្ម[63] មន្ទីរសន្តិសុខភ្នំចក្រី[64] និងវត្តព្រះនេត្រព្រះ[65]។ អ៊ឹម ចែម ក៏ធ្លាប់បានបញ្ជាដោយផ្ទាល់ឲ្យសម្លាប់ស្ត្រីវៀតណាមពីរនាក់ផងដែរ[66]។

32. សចស បានរកឃើញថាអ្នកទោសដែលបានជាប់ឃុំនិងសម្លាប់នៅមន្ទីរសន្តិសុខភ្នំទ្រយ្យូង មានទាំងវៀតណាមដែរ[67] ហើយបុគ្គលផ្សេងទៀតមកពីទំនប់ស្ពានស្រែង គឺត្រូវបានចាប់ខ្លួនដោយសារមានដើមកំណើតជាវៀតណាម[68]។ ក៏ប៉ុន្តែ សចស ខកខានមិនបានពិចារណាទៅលើចំណែកភាគច្រើននៃការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តរបស់ អ៊ឹម ចែម ចំពោះជនជាតិវៀតណាមឡើយ។ ដីកាដំណោះស្រាយ(សំអាងហេតុ) ខកខានមិនបានពិចារណាលើអំណះអំណាងរបស់ សពអ ឡើយទាក់ទងនឹងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងនេះ និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម។

## ឃ. សចស ខកខានមិនបានពិចារណាលើភ័ស្តុតាងអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម

33. ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា រៀបរាប់លម្អិតអំពីការពាក់ព័ន្ធរបស់ អ៊ឹម ចែម ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរផ្សេងទៀតទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការប្រព្រឹត្តចំពោះខ្មែរក្រោម នៅក្នុងតំបន់១៣ នៃភូមិភាគនិរតី[69]។ អ៊ឹម ចែម បានអនុវត្តគោលនយោបាយ បកក ដើម្បី "បោសសម្អាត" ខ្មែរក្រោម ឲ្យអស់ចេញពីតំបន់នានាដែលគាត់មានសិទ្ធិអំណាច[70]។ គាត់បានចូលរួមប្រជុំតំបន់ ដែលក្នុងកិច្ចប្រជុំទាំងនោះមានជាអាទិ៍ ការចេញសេចក្ដីណែនាំឲ្យស្វែងរក "ខ្មាំងខាងក្នុង"[71]។ សចស បានកត់សំគាល់ថា ខ្មែរក្រោម គឺជាក្រុមធំមួយដែលបានជាប់ឃុំនៅវត្តអង្គសិរីមាលី និងបានយក

[62] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៨៩។

[63] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩១។

[64] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៧៤។

[65] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៧៤។

[66] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩២។

[67] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ២០២, ២៩១។

[68] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ២៣៨។

[69] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៧២-៤៧៥, ៤៩៦-៥០៣។

[70] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៥៨-១៦២។

[71] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៦៧។

ទៅសម្លាប់នៅព្រៃសុខុនជាទៀងទាត់[72]។ ទីទាំងទាំងពីរនេះ ស្ថិតនៅក្នុងស្រុកកោះអណ្ដែត[73]។ អ៊ឹម ចែម គឺជាលេខាស្រុកកោះអណ្ដែត[74]។

34. ការខកខាននៃដីកាដំណោះស្រាយ(សំអាងហេតុ) ដើម្បីពិនិត្យនិងបញ្ចូលភស្តុតាងនៃការដាក់បន្ទុក អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនេះ តម្រូវឲ្យធ្វើការវាយតម្លៃឡើងវិញរបស់ សចស ចំពោះការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ដូចបានរៀបរាប់លម្អិតនៅក្នុងទឡ្ហីករណ៍ទី៥ និង ទី៦ សចស មានកំហុសបន្ថែមទៀតដែលរកឃើញថា អ៊ឹម ចែម គ្មានការទទួលខុសត្រូវចំពោះទីតាំងឧក្រិដ្ឋកម្មទាំងនេះ និងឧប្បត្តិហេតុព្រហ្មទណ្ឌផ្សេងទៀតនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី។

### ង. សចស ខកខានមិនបានពិចារណាលើភស្តុតាងអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មជាច្រើនទៀតដែលពួកគាត់បានទទួល

35. ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា រៀបរាប់លម្អិតអំពីការពាក់ព័ន្ធរបស់ អ៊ឹម ចែម ក្នុងការប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញប្រឆាំងក្រុមជាតិពន្ធុ និងក្រុមនយោបាយខុសៗគ្នា រួមទាំង ការធ្វើទុក្ខបុកម្នេញចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ[75] ការធ្វើទុក្ខបុកម្នេញចំពោះអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនិងក្រុមគ្រួសាររបស់ពួកគេ[76] និងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិចដែលរួមមានទាំងចាម[77] ចិន[78] ឡាវ[79] និង ខ្មែរលើ[80]។

36. សចស បានកម្រិតការរកឃើញរបស់ខ្លួនចំពោះការធ្វើទុក្ខបុកម្នេញ តែក្រុមនានាដោយមូលហេតុនយោបាយដែលបានជាប់ឃុំនៅភ្នំទ្រយ៉ូង ប៉ុណ្ណោះ[81]។ ខណៈដែល សចស បានរកឃើញសោះតែ

---

[72] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៤៩។

[73] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៤៨។

[74] *សូមអាន* ទឡ្ហីករណ៍ទី ៥។

[75] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៧៣-១៧៨, ៤៥១, ៤៧១។

[76] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៥១, ៤៧៣។

[77] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៨២, ១៦៨, ២៤០, ៤៤៧។

[78] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៥២, ២៤០។

[79] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៤០។

[80] **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៦៨។

[81] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ២៩៥។

ខានថា ការធ្វើទុក្ខបុកម្នេញបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មមិនត្រូវបានចោទប្រកាន់[82] ប៉ុន្តែគ្មានសញ្ញាបង្ហាញអំពីថាតើក្រុមណាមួយ ឬច្រើន ដែល សចស បានពិចារណាថាជាជនរងគ្រោះឡើយ និងគ្មានការវាយតម្លៃអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ទេ។

37. ជាការបន្ថែម សចស មិនបានពិនិត្យលើការចោទប្រកាន់ផ្នែកអង្គហេតុជាច្រើនផ្សេងទៀតដែលបានប្តឹងទៅពួកគាត់ឡើយ។ សចស ខកខានមិនបានវាយតម្លៃលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការធ្វើទារុណកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ូង[83] និងមន្ទីរសន្តិសុខចំការខ្នុរ[84] ការដាក់ក្នុងមន្ទីរឃុំឃាំង និងការបាត់ខ្លួនដោយបង្ខំនៅមន្ទីរសន្តិសុខវត្តអង្គសិរីមាលី[85] និងលក្ខខណ្ឌរស់នៅបែបអមនុស្សធម៌នៅមន្ទីរសន្តិសុខភ្នំចក្រី[86]ឡើយ។ សេចក្តីសន្និដ្ឋានចុងក្រោយរបស់ សចស លើការទទួលខុសត្រូវរបស់ អ៊ឹម ចែម គឺមានកំហុសដោយសារការចោទប្រកាន់ជាច្រើនដែលមាននៅក្នុង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា មិនត្រូវបានពិចារណា។

**ឧទ្ធរណ៍ទី៣៖ សចស មានកំហុសអង្គច្បាប់ និងអង្គហេតុនៅពេលដែលកំណត់និយមន័យឧក្រិដ្ឋកម្មការសម្លាប់រង្គាល និងការអនុវត្តនិយមន័យនេះលើការរកឃើញទាំងនោះ**

38. សចស បានខកខានមិនបានដាក់ឲ្យ អ៊ឹម ចែម ទទួលខុសត្រូវចំពោះការសម្លាប់រង្គាលនៅភ្នំត្រយោង។ សចស មានកំហុសអង្គច្បាប់ដោយការរកឃើញថា ចេតនាសម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល គឺការសម្លាប់ក្នុងកម្រិត "ដ៏ច្រើន" ត្រូវតែបានបង្កើតឡើង "ជាមុន"[87]។ សចស ក៏មានកំហុសអង្គហេតុផងដែរ ដោយការខកខានមិនបានរកឃើញថា អ៊ឹម ចែម ចេតនាឧក្រិដ្ឋដែលចាំបាច់សម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល។

39. ដីកាដំណោះស្រាយ (សំអាងហេតុ) បានរកឃើញថា ការសម្លាប់ "ត្រូវបានប្រព្រឹត្តឡើងជាប្រចាំ" នៅតាមមន្ទីរសន្តិសុខ ដែលជនរងគ្រោះត្រូវបាន "សម្លាប់ដោយសារមូលហេតុដូចគ្នា គឺ

---

82 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ៣០៥។

83 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០៨-២១១។

84 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៣៨។

85 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៦៨។

86 **D304/2** ដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២២៤។

87 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២៨៨។

អាកប្បកិរិយាដែលផ្ទុយទៅនឹងមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ បកក” ហើយការសម្លាប់ទាំងនោះ “ត្រូវបានធ្វើឡើងដោយចេតនាសម្លាប់ជាទ្រង់ទ្រាយធំដែរ ឬយ៉ាងណា”[88]។ ប៉ុន្តែ សចស បានលើកឡើងថាពួកគាត់មិនជឿជាក់ថា ការសម្លាប់ទាំងនេះបង្កើតបានជាការសម្លាប់រង្គាលនោះទេ។ ពួកគេបានពន្យល់សំអាងហេតុរបស់ខ្លួនតាមរយៈការកត់សម្គាល់ថាការសម្លាប់ទាំងនោះ៖ “ត្រូវបានធ្វើឡើងក្នុងរយៈពេលយូរ ហើយប្រហែលជាត្រូវបានធ្វើឡើងដោយចារីផ្ទាល់ ផ្សេងៗគ្នាផង។ កាលៈទេសៈទាំងអស់នេះធ្វើឲ្យមានភាពមិនច្បាស់លាស់ថាតើការសម្លាប់ទាំងអស់នេះត្រូវបានធ្វើឡើងដោយមានចេតនាសម្លាប់*ជាមុន* ជាទ្រង់ទ្រាយធំដែរ ឬយ៉ាងណា”[89]។

40. សចស មានកំហុសក្នុងការតម្រូវថា ជនជាប់ចោទត្រូវតែមានចេតនាជាក់លាក់សម្រាប់ឧក្រិដ្ឋកម្មសម្លាប់រង្គាល គឺសម្លាប់មនុស្សក្នុងគ្រង់ទ្រាយធំ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលគណនាទៅនាំឲ្យមានការស្លាប់មនុស្សក្នុងចំនួនដ៏ច្រើន[90] មុនពេលការសម្លាប់ណាមួយកើតមានឡើង។ យុត្តិសាស្ត្រនៅ អ.វ.ត.ក ឬ តុលាការអន្តរជាតិនានាមិនមានរួមបញ្ចូលទាល់តែសោះនូវលក្ខខណ្ឌតម្រូវបែបនេះសម្រាប់ឧក្រិដ្ឋកម្មសម្លាប់រង្គាល ហើយក៏មិនមានមូលដ្ឋានតក្កវិជ្ជាណាដាក់បញ្ចូលលក្ខខណ្ឌតម្រូវបែបនេះដែរ។

41. គេអាចស្រម៉ៃយអំពីស្ថានភាពមួយដែលមេបញ្ជាការនៅក្នុងយុទ្ធនាការជាបន្តបន្ទាប់ បញ្ជាឲ្យសម្លាប់ក្រុមប្រជាជនស៊ីវិលតូចមួយនៃភាគីបដិបក្ខនឹងជម្លោះ នៅរាល់ពេលដែលមានឱកាស ដែលជាចុងក្រោយបានសម្លាប់មនុស្សរាប់ពាន់នាក់នៅក្នុងយុទ្ធនាការនោះ។ វាហាក់ដូចជាមិនមានអត្ថន័យទាល់តែសោះ និងគាំទ្រនិទណ្ឌភាពក្នុងការសម្រេចថា ចេតនារបស់គាត់ក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំមិនមានភ័ស្តុតាងបញ្ជាក់បាន ដោយសារតែក្រុមទីមួយនៃជនរងគ្រោះដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងកម្លាំងគាត់នោះ មិនស្ថិតក្នុងចំនួនច្រើន។

42. សូម្បីតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលជាឧក្រិដ្ឋកម្មដែលចេតនាឧក្រិដ្ឋរបស់វា ត្រូវបាននិយាយថា “ត្រូវផ្តល់លក្ខណៈពិសេសរបស់វា និងចែកឲ្យដាច់វាពីឧក្រិដ្ឋកម្មទូទៅ និងឧក្រិដ្ឋកម្ម

---

88 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ២៨៨។

89 **D308/3** ដីកាដំណោះស្រាយ, កថាខណ្ឌ ២៨៨។

90 សំណុំរឿង០០២/០១-**F36** (សាលដីកាបណ្តឹងសាទុក្ខ) ២៣ វិច្ឆិកា ២០១៦, កថាខណ្ឌ ៥២១-៥២២, ៥២៥។

ដទៃផ្សេងទៀតប្រឆាំងនឹងច្បាប់មនុស្សធម៌អន្តរជាតិ”[91] មិនតម្រូវឱ្យមានការបញ្ជាក់ភស្តុតាងថាជនជាប់ចោទមានចេតនាប្រល័យពូជសាសន៍ *ជាមុន*មុនការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។ យុត្តិសាស្ត្រលើចំណុចនេះមានភាពច្បាស់លាស់ណាស់។

43. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានសម្រេចនៅក្នុងរឿងក្តី Simba ថាចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ “ការស្វែងរកមិនមែនថាតើ ចេតនាជាក់លាក់ត្រូវបានបង្កើតឡើងមុនពេលប្រព្រឹត្តអំពើនោះទេ”[92]។ បញ្ហានេះត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងរឿងក្តី *Munyakazi* ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍តម្កល់ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបង្ហាញអំពីចេតនារបស់ *Munyakazi* “ផ្អែកតាមការចូលរួមដោយផ្ទាល់របស់គាត់ និងតួនាទីដឹកនាំរបស់គាត់ក្នុងការវាយប្រហារ ដែលនាំឱ្យការស្លាប់មនុស្សរាប់ពាន់នាក់ភាគច្រើនជាប្រជាជនទុតស៊ី”។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបញ្ជាក់ឡើងវិញថា ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ “ការស្វែងរកមិនមែនថាតើ ចេតនាជាក់លាក់ត្រូវបានបង្កើតឡើងមុនពេលប្រព្រឹត្តអំពើនោះទេ”[93]។

44. សនិទានភាពដូចគ្នានេះមាននៅក្នុងតុលាការ ICTY ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖

> លក្ខន្តិកៈ [ICTY] មិនតម្រូវថា អំពើប្រល័យពូជសាសន៍ត្រូវតែគ្រោងទុកក្នុងរយៈពេលយូរនោះទេ។ គេអាចប្រមើលដឹងថា ទោះបីជាចេតនានោះនៅពេលដំបូងនៃប្រតិបត្តិការមិនមែនជាការបំផ្លាយក្រុមមួយក៏ដោយ វាអាចប្រែជាគោលដៅនៅដំណាក់កាលក្រោយមកទៀត ក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការនោះ[94]។

---

91 *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Goran Jelisić *(សាលក្រមសាលាដំបូង)*, IT-95-10-T, ICTY, ១៤ ធ្នូ ១៩៩៩, កថាខណ្ឌ ៦៦។

92 *Aloys Simba ទល់នឹង រដ្ឋអាជ្ញា (សាលដីកាបណ្តឹងសាទុក្ខ)*, ICTR-01-76-A, ICTR, ២៧ វិច្ឆិកា ២០០៧, កថាខណ្ឌ ២៦៦។

93 *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Yussuf Munyakazi (សាលដីកាបណ្តឹងសាទុក្ខ)*, ICTR-97-36A-A, ICTR, ២៨ កញ្ញា ២០១១, កថាខណ្ឌ ១៤២។

94 *Prosecutor ទល់នឹង Radislav Krstic (សាលក្រមអង្គជំនុំជម្រះសាលាដំបូង)*, IT 98-33, ICTY , ២ សីហា ២០០១, កថាខណ្ឌ ៥៧២។

45. ជាទូទៅ ចំណេះដឹងដែលថាការសម្លាប់ជាច្រើនកំពុងកើតមាន ហើយការចូលរួមជាបន្តបន្ទាប់របស់ជនជាប់ចោទក្នុងការសម្លាប់ដែលពាក់ព័ន្ធនោះ បង្ហាញឲ្យឃើញអំពីចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ[95]។ ប្រសិនបើមិនដោយសារតែកំហុសរបស់ខ្លួនក្នុងការសម្រេចថា ភ័ស្តុតាងនៃចេតនា *គិតទុកជាមុន* គឺជាលក្ខខណ្ឌតម្រូវសម្រាប់ការសម្លាប់រង្គាលនោះ ការរកឃើញអង្គហេតុរបស់សចស ពិតជាគាំទ្រដល់ការរកឃើញថា អ៊ឹម ចែម ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំត្រយោង។ សចស បានរកឃើញថា៖ អ៊ឹម ចែម មានសិទ្ធិអំណាចរួមលើភ្នំត្រយោង បានចេះបទប្បបញ្ញត្តិ និងបានត្រួតពិនិត្យផ្ទាល់លើដំណើរការរបស់វា[96] បានតែងតាំងប្រធានភ្នំត្រយោង[97] ដែលបានរាយការណ៍ផ្ទាល់មកគាត់អំពីបញ្ហានានាទាក់ទងនឹងមន្ទីរសន្តិសុខ និងបានទទួលបញ្ជាពីគាត់ផ្ទាល់ ជាលក្ខណៈបុគ្គល ឬតាមរយៈនិរសា[98] បានបញ្ជាឲ្យចាប់ខ្លួន[99] ការកំណត់លក្ខណៈមនុស្ស[100] ការដាក់ក្នុងមន្ទីរឃុំឃាំង[101] និងការសម្លាប់អ្នកទោសនៅភ្នំត្រយោង[102] បានទៅទស្សនាភ្នំត្រយោង[103] ហើយប្រហែលជាមានវត្តមានក្នុងការប្រជុំកម្មាភិបាលជាន់ខ្ពស់ ដែលត្រូវបានធ្វើឡើងមុនពេលមាន "ការសម្លាប់ទ្រង់ទ្រាយធំ" នៅទីនោះ[104] ឲ្យនិរសាររបស់គាត់ មកទស្សនាភ្នំត្រយោងពីរ ឬបីថ្ងៃម្តង[105] បានធ្វើការប្រជុំដ៏ទាងទាត់ដើម្បីកំណត់ថាតើអ្នកណាត្រូវបញ្ជូនទៅភ្នំត្រយោង និងបានប្រើឈ្លបឲ្យចាប់ខ្លួនមនុស្សបញ្ជូនទៅភ្នំត្រយោង[106]។

95 *សូមមើល,* ជាទូទៅ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Clement Kayishema *និង* Obed Ruzidana *(សាលដីកាបណ្តឹងសាទុក្ខ)*, ICTR-95-1-A, ICTR, ១ មិថុនា ២០០១, កថាខណ្ឌ ១៩៨ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានកត់សម្គាល់ថា "ចេតនាចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម អាចត្រូវបានទាញចេញពីការចូលរួមរបស់ជនជាប់ចោទ" និង "ត្រូវតែច្បាស់នៅក្នុងផ្នែករបស់ជនជាប់ចោទថាគាត់បានដឹងយ៉ាងច្បាស់ថាការចូលរួមនេះនឹងនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម"។

96 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៩៥។

97 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៩២។

98 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៩៥។

99 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២០០។

100 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២០៣។

101 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២០០។

102 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២០១។

103 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២១៧, ២២២។

104 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២១៣, ២១៧។

105 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២២២។

106 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២០០។

46. ដូច្នេះ អ៊ឹម ចែម មិនត្រឹមតែដឹងអំពីអ្វីដែលបានកើតឡើងប៉ុណ្ណោះទេ ប៉ុន្តែចែមទាំងបានត្រួតពិនិត្យការកើតឡើងទាំងនោះនៅភ្នំត្រយោងផងដែរ ជាមន្ទីរសន្តិសុខថ្នាក់តំបន់ ដែលមានអ្នកទោសមកដល់ប្រចាំសប្តាហ៍ ប៉ុន្តែ ជាញឹកញាប់មកជាប្រចាំថ្ងៃផងដែរ ជាក្រុមពីរនាក់ ទៅ២០០នាក់ម្តង[107]។ សចស បានរកឃើញថា អ្នកទោសរាប់រយនាក់ត្រូវបានធ្វើបាប[108] ទទួលបានអាហារ និងទឹកមិនគ្រប់គ្រាន់[109] ហើយត្រូវធ្វើពលកម្មជាទម្ងន់[110] ខណៈកំពុងជាប់ឃុំឃាំងនៅភ្នំត្រយោង ហើយជាលទ្ធផលអ្នកទោសរាប់រយនាក់បានស្លាប់ដោយអត់អាហារ[111] ជំងឺ[112] ធ្វើការហួសកម្លាំង[113] និងការធ្វើបាប[114]។ អ្នកជាប់ឃុំឃាំងត្រូវបានសម្លាប់ជាប្រចាំ ឬអ្នកទោសត្រូវបាននាំពីទីតាំងផ្សេងមកសម្លាប់នៅភ្នំត្រយោង[115]។ សចស បានប៉ាន់ប្រមាណតាមធម្មតាថា មានអ្នកទោសជាង ២០០០នាក់ ត្រូវបានសម្លាប់នៅភ្នំត្រយោង នៅចន្លោះពាក់កណ្តាលឆ្នាំ១៩៧៧ និងខែមករា ឆ្នាំ១៩៧៩[116] ដែលយ៉ាងហោចណាស់ប្រហែលជាអ្នកទោស ១០០០នាក់ ត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៧ និងប្រហែល ១០០០នាក់ ក្នុងឆ្នាំ១៩៧៨[117]។ នេះមិនមែនជាករណីនៃព្រឹត្តិការណ៍មិនជាប់ពាក់ព័ន្ធខុសគ្នានោះទេ។ អ៊ឹម ចែម ទទួលខុសត្រូវចំពោះប្រតិបត្តិការនៅភ្នំត្រយោង និងបានដឹងអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំ និងចេតនារបស់គាត់ក្នុងការសម្លាប់ក្នុងទ្រង់ទ្រាយធំដែលបានកើតឡើងនៅទីនោះ។ ចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំរបស់គាត់នេះគឺពិតជាបានបង្ហាញយ៉ាងច្បាស់ដោយការរកឃើញរបស់ សចស។

---

107 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៩៧។

108 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៨៩, ២០៧។

109 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៨៩, ២០៦។

110 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៨៩, ២១៩។

111 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៨៩, ២១៩, ២២០។

112 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៨៩, ២១៩។

113 **D308/**ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២១៩។

114 **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ ២១៩។

115 **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ២០៨។

116 **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ១៨៩។

117 **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ ២១៨។

## ចន្លឹករណ៍ទី៤÷ សចស មានកំហុសអង្គច្បាប់ និងអង្គហេតុនៅពេលដែលកំណត់និយមន័យឧក្រិដ្ឋកម្មនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការអនុវត្តនិយមន័យនេះលើការរកឃើញទាំងនោះ

47. សចស មានកំហុសដោយខកខានមិនបានរកឃើញថា ឧក្រិដ្ឋកម្មនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ គឺជាអំពើអមនុស្សធម៌មួយផ្សេងទៀត ដែលបានកើតមានឡើងនៅប្រឡាយស្ពានស្រែង។ ទីមួយ សចស បានអនុវត្តខុសនូវនិយមន័យនៃឧក្រិដ្ឋកម្មសម័យទំនើបនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ដែលមិនមានអត្ថិភាពក្នុងឆ្នាំ១៩៧៥ ជំនួសឲ្យធាតុផ្សំនានានៃអំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទីពីរ ថាតើត្រូវបានចាត់ថ្នាក់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ឬជាឧក្រិដ្ឋកម្មសម័យទំនើបនៃឧក្រិដ្ឋកម្មនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ឬអត់នោះ សចស បានអនុវត្តដោយភាន់ច្រឡំនូវធាតុផ្សំមួយនៃឧក្រដ្ឋកម្មនេះ គឺភ័ស្តុតាងដែលថាជនទាំងឡាយណាដែលបានស្វែងរកព័ត៌មានអំពីទីកន្លែងរបស់បុគ្គលម្នាក់ដែលស្ថិតនៅក្នុងដៃរបស់អាជ្ញាធរ ដែលមិនអាចអនុវត្តបាននៅទីណាដែលអាជ្ញាធរទាំងនោះសម្លាប់អ្នកណា ដែលជំទាស់ទៅនឹងសកម្មភាពរបស់ខ្លួន[118]។

### ក. សចស ខកខានមិនបានអនុវត្តយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលអំពីការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ

48. ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម[119]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅក្នុងសាលដីកាបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១ ថា អំពើឧក្រិដ្ឋ និងចេតនាឧក្រិដ្ឋសម្រាប់ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងៗទៀត មិនខុសគ្នាពីអំពើឧក្រិដ្ឋ និងចេត្តនាឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនោះទេ ផ្អែកលើប្រភេទណាមួយផ្សេងទៀតនៃទង្វើដែលត្រូវបានហាមឃាត់នោះ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយការកំណត់និយមន័យ និងការអនុវត្តធាតុផ្សំនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ជាជាងអនុវត្តនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា៖

---

118 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ៣០២។

119 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ៧៥, ៣០២។

បើទោះបីជា មានការបង្ហាញយ៉ាងច្បាស់ថា អំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ជាប្រភេទបទឧក្រិដ្ឋមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឆ្នាំ ១៩៧៥ ក៏ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំពុំមានចែងច្បាស់លាស់ថា ជាប្រភេទឧក្រិដ្ឋកម្មដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ពិតណាស់ ជាច្រើនឆ្នាំក្រោយមក ទើបមានការកំណត់ច្បាស់លាស់អំពីឧក្រិដ្ឋកម្មនេះ [...] អាស្រ័យហេតុនេះ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ឬការផ្លាស់ទីលំនៅដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ពុំទាន់មានរូបរាងជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឡើយទេ ដូចគ្នានេះដែរ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំនេះ ពុំមានធាតុផ្សំ ឬអត្ថន័យជាក់លាក់តាមច្បាប់នៅឡើយដែរ។ ផ្អែកតាមមូលហេតុនេះ ការកំណត់ពីធាតុផ្សំនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ឬការផ្លាស់ទីលំនៅដោយបង្ខំថាជាប្រភេទឧក្រិដ្ឋកម្មដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់ឡើយ [...] ផ្ទុយទៅវិញ បញ្ហាដែលត្រូវបំភ្លឺ និងជាបញ្ហាតែមួយគត់ដែលមានការពាក់ព័ន្ធ គឺ ថាតើអំពើប្រព្រឹត្តដែលចោទជាបញ្ហានេះ ដោយផ្អែកលើកាលៈទេសៈជាក់លាក់ទាំងអស់នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ជាក់ស្តែងបានបំពេញតាមការកំណត់និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែរ ឬយ៉ាងណា[120]។

49. នៅក្នុងដីកាដំណោះស្រាយ សចស គួរបានអនុវត្តធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានកំណត់និយមន័យដោយអង្គជំនុំជម្រះតុលាការកំពូលជាទង្វើដែល “រំលោភបំពានលើសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ និងមានមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែល គ្នាទៅនឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”[121]។ ផ្ទុយទៅវិញ សចស បានរកឃើញមិនត្រឹមត្រូវថា “ទោះបីជាមានការសង្ស័យតិចតួចប៉ុណ្ណោះដែលថា ក្រុមគ្រួសារពលករដែលបានបាត់ខ្លួនអាចដឹងពីជោគវាសនារបស់ពួកគេ ឬដឹងអំពីទីកន្លែងស្នាក់នៅរបស់ពួកគេក៏ដោយ តែមិនមានភស្តុតាងបង្ហាញថា មានការសួរលើចំណុចនេះទៅអាជ្ញាធរដែលទទួលខុសត្រូវលើការដ្ឋានឡើយ”[122]។

120 សំណុំរឿង០០២/០១- **F36** (សាលដីកាបណ្តឹងសាទុក្ខ), ២៣ វិច្ឆិកា ២០១៦, កថាខណ្ឌ ៥៨៩។

121 សំណុំរឿង០០២/០១- **F36** (សាលដីកាបណ្តឹងសាទុក្ខ), ២៣ វិច្ឆិកា ២០១៦, កថាខណ្ឌ ៥៨៦។

122 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ៣០២។

សចស ជាចុងក្រោយបានសន្និដ្ឋានថា "ដោយសារមូលហេតុនេះតែមួយគត់ ភ័ស្តុតាងមិនអាចអនុញ្ញាតឲ្យយើងសន្និដ្ឋានបានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការធ្វើឲ្យបាត់ខ្លួនដោយបង្ខំត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពានស្រែងឡើយ"[123]។

50. អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយចំណុចជាក់លាក់នេះក្នុងសំណុំរឿង ០០២/០២ ដោយបានកំណត់វាជាកំហុសមួយក្នុងពាក្យពេចន៍ខាងក្រោមនេះ៖

> ទាក់ទងទៅនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខ្មែរក្រហមមានចេតនាបិទបាំងព័ត៌មានអំពីទីកន្លែងរបស់អ្នកដែលត្រូវបានជម្លៀស និងអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន អំពីបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញទាំងនេះពាក់ព័ន្ធទៅនឹងបញ្ហា ថាតើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀតត្រូវបានបំពេញ ដែរ ឬយ៉ាងណានោះទេ[124]។

51. ប្រសិនបើ សចស បានអនុវត្តនិយមន័យច្បាប់ត្រឹមត្រូវ អ៊ឹម ចែម នឹងត្រូវបានចាត់ទុកថាត្រូវទទួលខុសត្រូវចំពោះការបាត់ខ្លួនដោយបង្ខំនៅស្ពានស្រែង។ សចស បានរកឃើញថា "ការចាប់ខ្លួន និងការបាត់ខ្លួនកម្មករឃើញកើតមានជាទូទៅនៅការដ្ឋានប្រឡាយស្ពានស្រែង"[125]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/១ បានសម្រេចថា ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំឡើងដល់កម្រិតនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសារការឈឺចាប់ដ៏ធំធេងដែលកើតមានលើអ្នកដែលបានបាត់ខ្លួន ក៏ដូចជាចំពោះសមាជិកគ្រួសាររបស់ពួកគេ និងអ្នកផ្សេងទៀតដែលមានចំណងមេត្រីភាពពិសេសទៅនឹងអ្នកដែលបានបាត់ខ្លួននោះ[126]។ ការប៉ះទង្គិចផ្លូវចិត្ត និងការឈឺចាប់ចំពោះអ្នកនៅស្ពានស្រែងក៏មិនខុសគ្នាដែរ។

## ខ. បន្ទុកស្នើសុំព័ត៌មានអំពីបុគ្គលដែលត្រូវបានបាត់ខ្លួនដោយបង្ខំមិនគិតអំពីធាតុពិតនៃ បកក

123 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ៣០២ (គូសបញ្ជាក់បន្ថែម)។

124 សំណុំរឿង០០២/០១- **F36** (សាលដីកាបណ្តឹងសាទុក្ខ), ២៣ វិច្ឆិកា ២០១៦, កថាខណ្ឌ ៦៥៣។

125 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ២៣៨។

126 សំណុំរឿង០០២/០១- **E313** (សាលក្រមសាលាដំបូង), ៧ សីហា ២០១៤, កថាខណ្ឌ ៦៤៣។

52. សហព្រះរាជអាជ្ញាយល់ឃើញថា ដោយមិនគិតអំពីថាតើ ឧក្រិដ្ឋកម្មនោះត្រូវបានកំណត់លក្ខណៈថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬជាអំពើអមនុស្សធម៌ផ្សេងទៀត ឬអត់នោះ ក៏ឧក្រិដ្ឋកម្មនោះត្រូវបានបញ្ជាក់ភ័ស្តុតាងនៅពេលដែលវាត្រូវបានបង្ហាញឱ្យឃើញថា បុគ្គលនានាត្រូវបានយកចេញដោយអាជ្ញាធរដោយគ្មានផ្តល់ព័ត៌មានដល់ក្រុមគ្រួសារ ឬមិត្តភក្តិរបស់ពួកគេអំពីទីតាំងរបស់ពួកគេទាំងនោះឡើយ។ សចស មានកំហុសនៅពេលដែលតម្រូវថាធាតុផ្សំមួយជាបទល្មើសគឺជនទាំងឡាយត្រូវតែសាកសួរអំពីទីតាំងរបស់ជនរងគ្រោះ ដោយមិនគិតអំពីកាលៈទេសៈដ៏តឹងតែងបំផុត ដែលបានកើតមាននាពេលនោះ។ នៅក្នុងរដ្ឋគ្មានច្បាប់ទម្លាប់ដូចជារដ្ឋដែលដឹកនាំដោយបកក ដែលអ្នកដែលសួរសំណួរអំពីជនទាំងឡាយដែលត្រូវបានឃុំខ្លួន ឬបានបាត់ខ្លួននោះ បានធ្វើឱ្យពួកគេស្ថិតក្នុងហានិភ័យខ្លាំងដែលនាំឱ្យគេជួបជោគវាសនាដូចគ្នា ការតម្រូវឱ្យមានភ័ស្តុតាងបញ្ជាក់ថា គ្រួសារ ឬមិត្តភក្តិបានធ្វើការស្វែងរកព័ត៌មានអំពីជោគវាសនា ឬទីកន្លែងរបស់ជនដែលបានបាត់ខ្លួនគឺមិនសមហេតុផលនោះទេ។

53. ច្បាប់កយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (IACtHR) មានលក្ខណៈពិស្តារ។ នៅក្នុងប្រទេសដែលការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានកើតមានឡើងក្នុងទ្រង់ទ្រាយធំ តុលាការ IACtHR បានជ្រើសរើសប្តូបន្ទុកនៃការបដិសេធការបាត់ខ្លួនដោយបង្ខំទៅឱ្យរដ្ឋ។ រឿងក្តីដំបូងដែលដោះស្រាយបញ្ហានេះគឺ *រឿងក្តី Velasquez Rodriguez ទល់នឹង Honduras* បានបង្កើតករណីយុត្តិសាស្ត្រខាងក្រោមនេះ៖

> ប្រសិនបើអាចត្រូវបានបង្ហាញថា មានការអនុវត្តផ្លូវការនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅក្នុង Honduras ដែលបានអនុវត្តឡើងដោយរដ្ឋាភិបាល ឬយ៉ាងហោចណាស់បណ្តោយឱ្យកើតមានដោយរដ្ឋនោះ ហើយប្រសិនបើការធ្វើឱ្យបាត់ខ្លួន Manfredo Velasquez អាចត្រូវបានភ្ជាប់ទៅនឹងការអនុវត្តនោះ ការចោទប្រកាន់របស់គណៈកម្មការនោះ នឹងត្រូវបានបញ្ជាក់ភ័ស្តុតាងទៅតាមការចង់បានរបស់តុលាការ ដ៏រាបណាភ័ស្តុតាងនោះបានបង្ហាញចំណុចទាំងពីរបំពេញតាមបទដ្ឋាននៃភ័ស្តុតាងដែលត្រូវការ[127]។

127 រឿងក្តី Velásquez Rodríguez Case *ទល់នឹង Honduras*, តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង ១៩៨៩ (ser. C), ២៨ កក្កដា ១៩៨៨, កថាខណ្ឌ ១២៦។

54. បន្ទាន់នៃសនិទានភាពរបស់តុលាការនេះត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាបន្តបន្ទាប់ ដូចជាសេចក្តីសម្រេចលើ Godinez Cruz និង Caballero-Degado & Santana[128] គឺថាប្រសិនបើមានការអនុវត្តនៃការបាត់ខ្លួន ហើយការបាត់ខ្លួនដែលជាបញ្ហានោះមានទំនាក់ទំនងគ្នា ដូច្នេះបុគ្គលនោះត្រូវគេសន្មតថាបានបាត់ខ្លួន ហើយបន្ទុកត្រូវប្តូរទៅខាងរដ្ឋនោះវិញដើម្បីបញ្ជាក់ផ្សេងពីនេះ។

55. ទោះបីជាមិនមែនជាតុលាការព្រហ្មទណ្ឌ ហើយដូច្នេះអនុវត្តបទដ្ឋានភ័ស្តុតាងខុសគ្នាក៏ដោយ គោលការណ៍ដែលបានអនុវត្តដោយតុលាការ IACtHR អាចអនុវត្តបានផ្ទាល់ទៅនឹងកាលៈទេសៈបច្ចុប្បន្ននេះ។ ដើម្បីឲ្យច្បាស់ ការប្តូរបន្ទុកទៅឲ្យរដ្ឋនៅក្នុងបរិបទសិទ្ធិមនុស្ស មិនមែនណែនាំថាជាការប្តូរបន្ទុកទៅឲ្យមេធាវីការពារក្តីនៅក្នុងបរិបទព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែ វាជាការទទួលស្គាល់ថា កាលៈទេសៈលើសលុបត្រូវទទួលបានការពិចារណា ដើម្បីធានាថាច្បាប់អាចដំណើរការបាន។ ដូចក្នុងករណីអាជ្ញាធរគ្មានច្បាប់ដូចរបបកម្ពុជាប្រជាធិបតេយ្យនេះ ច្បាប់នឹងឈប់ការពារផលប្រយោជន៍ដែលវាត្រូវបានតាក់តែងឡើង ប្រសិនបើរបបមួយអាចលាក់បាំងពីក្រោយភាពត្រឹមត្រូវតាមច្បាប់នីតិវិធីដើម្បីគេចវេះពីការទទួលខុសត្រូវនោះ នៅពេលដែលវិធីសាស្ត្រដ៏ឃោរឃៅ និងគ្មានមេត្តារបស់ខ្លួនក្នុងការគ្រប់គ្រងគឺជាមូលហេតុដែលខ្លួនអាចធានាដល់និទណ្ឌភាពរបស់ខ្លួននោះ។

56. ភ័ស្តុតាងដែល សចស បានពឹងផ្អែកលើបានបង្ហាញអំពីចំណុចនេះ។ ដីកាដំណោះស្រាយរៀបរាប់លម្អិតនូវភ័ស្តុតាងដ៏ច្រើនអំពីការជម្រុញជាសាធារណៈរបស់ អ៊ឹម ចែម ឲ្យប្រជាជន "ប្រយ័ត្នប្រយែងជាមួយនឹងជនដែលអាចជាខ្មាំងរបស់ បកក ហើយបង្គាប់ឲ្យកម្មករគោរពតាមមនោគមន៍វិជ្ជារបស់ បកក និងខិតខំធ្វើការ ដោយគំរាមកំហែងថានឹងមានលទ្ធផលមិនល្អប្រសិនបើពួកគេមិនធ្វើតាមដូច្នេះទេ"[129]។ សចស បានរកឃើញថា "អ៊ឹម ចែម បានព្រមានអ្នកចូលរួមអង្គប្រជុំថាអ្នកដែលជាប់ខ្សែរ ស៊ី អាយ អេ អ្នកខ្ជិល ឬប្រឆាំងអង្គការ នឹងបញ្ជូនទៅ "*រៀនសូត្រ*"ដែលពាក្យនេះជាញឹមញាប់មានន័យថា ត្រូវបញ្ជូនទៅឃុំខ្លួន ឬសម្លាប់ចោល"[130]។ ដីកាដំណោះស្រាយបានបន្តទៀតថា៖ "ការលើកឡើងទាំងនេះមិនមែនជាការគំរាមកំហែងខ្យល់ទេ។ បន្ទាប់ពីកម្មាភិបាលនិរតី

---

128 *សូមមើល ឧ., រឿងក្តី* <u>*Godínez & Cruz Case*</u> *ទល់នឹង Honduras*, តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង ឆ្នាំ១៩៨៩ (ser. C), ២០ មករា ១៩៨៩, កថាខណ្ឌ ៧៦; *រឿងក្តី* <u>*Caballero-Delgado & Santana Case*</u> *ទល់នឹង Colombia*, ៨ ធ្នូ ១៩៩៥, តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង (ser. C) ល.២២, កថាខណ្ឌ ៧២(៥)។

129 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ១៨១។

130 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ១៨៤។

និង អ៊ឹម ចែម ចូលគ្រប់គ្រង [...] ពួកគេបានអនុវត្តយុទ្ធការធ្វើការចាប់ខ្លួនជាប្រព័ន្ធ ដោយដាក់មុខសញ្ញាលើកម្មាភិបាលពាយ័ព្យ នៅថ្នាក់សហករណ៍ ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់"[131]។ ការកំណត់មុខសញ្ញានេះមិនកម្រិតត្រឹមតែកម្មាភិបាលភូមិភាគពាយ័ព្យប៉ុណ្ណោះទេ ដូចដែល សចស បានរកឃើញថា "នៅក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម [...] កម្មករដែលមានកំហុស មនុស្សដែលជាប់ទាក់ទងនឹងវៀតណាម និងអតីតមន្ត្រី លន់ នល់ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល"[132]។

57. ស្ថិតក្នុងបរិយាកាសដែលជួបប្រទះទាំងនេះ ដែលក្នុងនោះការគំរាមកំហែងសម្លាប់ ឬត្រូវបាត់ខ្លួន បង្ហាញឲ្យឃើញយ៉ាងច្បាស់ចំពោះបញ្ហាតិចតួចណាមួយនោះ ការតម្រូវឲ្យបុគ្គម្នាក់ស្វែងរកព័ត៌មានពីអង្គការ ជាអាជ្ញាធរដែលមិនអាចសួរបាន គឺពិតជាមិនមានភាពប្រាកដនិយមទាល់តែសោះ[133]។

## **ទន្ទឹករណ៍ទី៥៖ សចស មានកំហុសអង្គហេតុនៅពេលរកឃើញថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត**

58. សចស មានកំហុសផ្នែកអង្គហេតុនៅពេលដែលរកឃើញថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត[134]។ សចស ខកខានមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវចំពោះភស្តុតាងដែលបានពិនិត្យនៅក្នុងដីកាដំណោះស្រាយ(សំអាងហេតុ) និងនៅក្នុងឧទាហរណ៍ខ្លះទៀត គឺគេបានបំភ្លេចចោលភស្តុតាងពាក់ព័ន្ធ។ មិនមានវិនិច្ឆ័យអង្គហេតុដ៏សមហេតុផលណាអាចរកឃើញថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត ផ្អែកតាមការពិនិត្យដ៏ត្រឹមត្រូវលើភស្តុតាងនេះនោះទេ។

59. ដីកាដំណោះស្រាយ(សំអាងហេតុ) សន្និដ្ឋានខុសថា មុខងាររបស់ អ៊ឹម ចែម នៅភូមិភាគនិរតី ត្រឹមតែជាប្រធានសមាគមនារីតំបន់១៣[135]។ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ សចស ខកខានមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើបទសម្ភាសន៍នានាដែលបានបង្ហាញពីមុខនាទីរបស់គាត់ ជាលេខាស្រុកកោះអណ្តែត។ អ៊ឹម ចែម បានប្រាប់ DC-Cam ថា "ខាងខេត្តហ្នឹងគាត់ផ្លាស់ឲ្យខ្ញុំទៅនៅ

---

131 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ១៨៥។

132 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ១៨៦។

133 *សូមមើល ឧ.,* **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ២៣៣, ២៣៨, ២៧៥, ២៨៩, ២៩៧, ២៩៨។

134 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៤។

135 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៣-១៥០ ។

រៀបចំប្រជាជន”នៅក្នុងស្រុកកោះអណ្តែត[136]។ អ៊ឹម ចែម បានសារភាពថា នៅស្រុកកោះអណ្តែត គាត់[ដឹកនាំ]គេធ្វើដូចថា ធ្វើស្រែ ធ្វើចំការ [...] [ហ្នឹងហើយ] ទូទៅហ្នឹង កន្លែងដែលខ្ញុំគ្រប់គ្រងដឹកនាំ”[137] ដោយបន្តទៀតថា៖

> ជួយទូទៅៗ [នៅកោះអណ្តែត]។ ប៉ុន្តែគ្រាន់ថា អ្នកណាដែលគេចោទប្រកាន់ត្រូវប៉ះពាល់ដល់ជីវិត ខ្ញុំជួយ។ ខ្ញុំទៅធានាអះអាងថាគាត់មិនមែនអញ្ចឹង។ ដូចថាមានស្មារតីតស៊ូ ចំពោះការពារអាយុជីវិតរបស់អ្នកត្រឹមត្រូវនឹង[138]។

60. នៅពេលសួរថាហេតុអ្វីបានជាគេបញ្ជូនគាត់ពីស្រុកអង្គរជ័យ ទៅកោះអណ្តែត អ៊ឹម ចែម ឆ្លើយថា “ខ្ញុំធ្វើអីក៏សម្រេចតាមផែនការ”[139]។ អ៊ឹម ចែម បានប្រាប់ DC-Cam ដូចតទៅ៖

> DC-Cam: ហើយកាលនឹងនៅកោះអណ្តែតយ៉ាងម៉េច បានគេចាត់អ៊ំឲ្យមកកោះអណ្តែតវិញ ហើយអ្នកគ្រប់គ្រងកោះអណ្តែតពីមុនយ៉ាងម៉េច បានគេដក?
> អ៊ឹម ចែម: អ្នកគ្រប់គ្រងខាងកោះអណ្តែតនឹងវាទំនាស់គ្នាផង ហើយធ្វើការងារអត់ឯកភាពគ្នា។ ដល់ខ្ញុំទៅនៅទៅ ដកប្រធាននឹងទៅគិរីវង់។
> DC-Cam: ចឹង កាលនៅកោះអណ្តែតពីណាគេ?
> អ៊ឹម ចែម: យាយ សៀង។
> DC-Cam: ឈ្មោះ សៀង?
> អ៊ឹម ចែម: ចា៎!
> DC-Cam: ឈ្មោះ សៀង គាត់ដកទៅគិរីវង់?
> អ៊ឹម ចែម: ចា៎! ហើយដល់ខ្ញុំទៅនឹង ៣នាក់: តាមួយធ្វើសមាជិក ហើយអនុខ្ញុំនឹងមានប្អូនថ្លៃតាម៉ុក។
> DC-Cam: ពីណាគេ?
> អ៊ឹម ចែម: តា សាន ប្អូនថ្លៃ តា ម៉ុក។
> DC-Cam: ចឹង កាលអ៊ំទៅកោះអណ្តែតមានអ៊ំ មាន តា សាន មាន?
> អ៊ឹម ចែម: មាន តា ចាន់ៗ គាត់ចាស់ហើយ[140]។

---

136 **D123/1/5.1b** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ២០ មិថុនា ២០០៨, EN 00951795។

137 **D123/1/5.1b** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ២០ មិថុនា ២០០៨, EN 00951819។

138 **D123/1/5.1b** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ២០ មិថុនា ២០០៨, EN 00951820។

139 **D123/1/5.1c** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ៦ មេសា ២០១២, EN 00951845។

140 **D123/1/5.1c** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam,៦ មេសា ២០១២, EN 00951846។

61. ដីកាដំណោះស្រាយ (សំអាងហេតុ) យោងទៅរកកំណត់ហេតុនេះដោយ អ៊ឹម ចែម ថា គាត់ស្ថិតនៅក្នុងគណៈកម្មាធិការដែលមានគ្នាបីនាក់ នៅពេលត្រូវគេបញ្ជូនទៅកោះអណ្ដែត[141]។ ប៉ុន្តែ សចស បានធ្វើការសន្និដ្ឋានមិនសូវទំនងថា គណៈកម្មាធិការដែលគ្នាបីនាក់នេះ "គឺផ្ដោតលើការងារបង្កបង្កើនផលស្រូវ"[142] ហើយបានធ្វើការនៅកោះអណ្ដែត "ដោយសារគាត់មានតួនាទីជាប្រធានសមាគមនារីតំបន់១៣ [របស់ អ៊ឹម ចែម]"[143]។ ផ្ទុយពីនេះ កំណត់ហេតុរបស់ អ៊ឹម ចែម បានបញ្ជាក់យ៉ាងច្បាស់។ សៀងដែលជាលេខាស្រុកកោះអណ្ដែត[144] គឺត្រូវបានគេបញ្ជូនចេញពីស្រុកបាត់ហើយ "ហើយបន្ទាប់មកមានមនុស្សបីនាក់" នៅស្រុកកោះអណ្ដែត ដោយមាន អ៊ឹម ចែម ជាលេខាស្រុក។

62. អ៊ឹម ចែម បានប្រាប់ DC-Cam ថា នៅពេលគាត់មកដល់កោះអណ្ដែតគេបាន "រៀបចំបាយរួមហើយ" ហើយ

> គោលការណ៍យើងរៀបចំ ទី១ ធ្វើចង្ក្រានបាយ និងចង្រុកស្រូវធំៗ ប៉ុន្តែ ខ្ញុំនៅនឹងដូចអត់ពិបាកអីដែរ ព្រោះចែកការងារគ្នាដាច់ ខ្ញុំនៅខាងក្រោយ ខ្ញុំគិតតែដឹកនាំប្រជាជនធ្វើស្រែវស្សាទៅហើយ ពូសាន អនុខ្ញុំ នៅខាងជាប់ខាងយួន ស្រុងបឹង[145]។

63. ការសារភាពរបស់ អ៊ឹម ចែម ទាក់ទងនឹងមុខងាររបស់គាត់ គឺត្រូវបានបញ្ជាក់អះអាងតាមរយៈភស្តុតាងរបស់សាក្សីនានា។ ប៉ុន្តែ សចស ខកខានមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវលើភស្តុតាងគាំទ្របន្ថែមនេះទេ។ សូមបង្ហាញនូវឧទាហរណ៍មួយចំនួនដូចខាងក្រោម។

64. ទីមួយ សចស បានច្រានចោលភស្តុតាងរបស់ អ៊ុល ហឿន ដោយផ្អែកលើមូលដ្ឋានថា គាត់បានអះអាងថា អ៊ឹម ចែម គឺជាលេខា "ស្រុកតានី ហៅស្រុក ១០៦"[146]។ ប៉ុន្តែ សចស ខកខានមិនបាន

---

[141] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៦។

[142] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៦។

[143] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៦។

[144] *សូមមើល* **D119/82** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នាង អ៊ួច, ២៨ មករា ២០១៤, ឆ១៧, ឆ២៧, ឆ៣៤។ **D119/84** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត, ១១ កុម្ភៈ ២០១៤, ឆ.២១, EN 00982704; **D6.1.651** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម, ២៦ សីហា ២០០៩, ERN 00379303។

[145] **D123/1/5.1c** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ៦ មេសា ២០១២, EN 00951847។

[146] **D118/208** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុល ហឿន, ៤ មីនា ២០១៤, ឆ៦២, *ដែលបានលើកយោង* នៅក្នុងឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៩។

ពិចារណាទៅលើទិដ្ឋភាពដ៏សំខាន់ពីរនៃភ័ស្តុតាងរបស់ អ៊ុល ហឿន ទេ។ ទីមួយ គាត់និយាយថា គាត់មិនប្រាកដថាស្រុកណាមួយជាស្រុក ១០៦ទេ ដោយបាននិយាយប្រាប់ សចស ថា "មុនរបបខ្មែរក្រហម *គឺស្ថិតនៅក្នុងស្រុកកោះអណ្តែត*"[147]។ ទីពីរ ស្រុក១០៦ គឺស្រុកអង្គរជ័យ ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ និងមើលការខុសត្រូវដោយ តាញ៉ែន - ត្រូវជាប្តីរបស់ អ៊ឹម ចែម[148]។ ដូច្នេះ ចម្លើយរបស់ អ៊ុល ហឿន ចំពោះស្រុកដែល អ៊ឹម ចែម កាន់កាប់ អាចត្រូវបានពន្យល់តាមរយៈការច្រឡំរបស់គាត់អំពីបរិវេណព្រំដែននៃស្រុកនេះ ឬការជាប់ពាក់ព័ន្ធរបស់វាទៅនឹង អ៊ឹម ចែម តាមរយៈមុខងាររបស់ប្តីគាត់។ និយាយឲ្យតិចបំផុត គឺមានការបញ្ជាក់អះអាងថា អ៊ឹម ចែម គឺជាលេខាស្រុកមួយនៅក្នុងតំបន់១៣។

65. ទីពីរ សចស បកស្រាយខុសចំពោះភ័ស្តុតាងរបស់ នាង អ៊ូច ដោយធ្វើការសន្និដ្ឋានទាំងច្រឡំថា ភ័ស្តុតាងរបស់គាត់គាំទ្រតែថា អ៊ឹម ចែម ជាប្រធានសមាគមនារីតំបន់១៣[149] ប៉ុណ្ណោះ។ ភ័ស្តុតាងពីសាក្សីផ្សេងទៀតបង្ហាញឲ្យឃើញថា នាង អ៊ូច គឺជាសមាជិកគណៈស្រុកកោះអណ្តែត[150]។ គាត់បានបដិសេធបានកាន់មុខតំណែងនេះ ដូចដែលគាត់បានបដិសេធក្រោយមកទៀតថាជាលេខាស្រុកត្រាំកក់ដែរ ប៉ុន្តែ មានភ័ស្តុតាងលើសលុបបញ្ជាក់ថា ការបដិសេធទាំងអស់នេះគឺគ្រាន់តែជាការកុហក ក្នុងគោលបំណងមួយដាក់ខ្លួនគាត់ឲ្យឆ្ងាយពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ទាំងអស់នេះតែប៉ុណ្ណោះ[151]។ ដីកាដំណោះស្រាយខកខានមិនបានពិចារណាចម្លើយរបស់ អ៊ឹម ចែម ដែលរៀបរាប់ថា នាង អ៊ូច ជា "អនុខ្ញុំ" ក្នុងស្រុកកោះអណ្តែត[152]។ អ៊ឹម ចែម បាននិយាយថា "ពូសាន [ហៅ នាង អ៊ូច] អនុខ្ញុំ នៅខាងជាប់ខាងយួន ស្រុងបឹង"[153]។ សចស ខកខានមិនបានពិចារណាឲ្យបានត្រឹមត្រូវថា នៅពេលដែលចម្លើយរបស់ អ៊ឹម ចែម ត្រូវបានដាក់សួរទៅកាន់ នាង អ៊ូច ដោយ សចស នោះ គាត់មិនបានជំទាស់ថាជា "អនុ" របស់គាត់ទេ។

---

147 **D118/208** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន, ៤ មីនា ២០១៤, ឆ៦៥ (សង្កត់ន័យដើម)។

148 *សូមមើល,* **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៩។

149 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៥។

150 *សូមមើល* ជាឧទាហរណ៍ **D193.8.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន, ១៣ តុលា ២០១៤, ឆ៧។ **D119/63** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាវ ណោម, ២៥ កញ្ញា ២០១៣, ឆ៤។ **D6.1.651** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម, ២៦ សីហា ២០០៩, EN 00379303។

151 *សូមមើល,* **E1/273.1** ប្រតិចារឹកសវនាការ នាង អ៊ូច, ៩ មីនា ២០១៥, 15.17.20-15.26.34។

152 **D123/1/5.1c** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ៦ មេសា ២០១២, 00951847។

153 **D123/1/5.1c** បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ដោយ DC-Cam, ៦ មេសា ២០១២, 00951847។

ពិតប្រាកដនោះ វានឹងមិនសមហេតុផលទេក្នុងការជឿជាក់ថា នាង អ៊ូច បាននិយាយថា គាត់ជាអនុរបស់ប្រធានសមាគមនារីនោះ។ នៅពេលដែលត្រូវបានតទល់ជាមួយនឹងចម្លើយរបស់ អ៊ឹម ចែម ថាគាត់គឺជាអនុរបស់នាងនោះ នាង អ៊ូច បានប្រាប់ កសចស ថា "បាទ, ត្រឹមត្រូវហើយ។ គឺខ្ញុំទៅធ្វើការនៅបឹងព្រែកល្ពៅ ធុងលិច ដើម្បីធ្វើប្រឡាយនៅទីនោះ"[154]។ មុននោះគាត់អះអាងថា គាត់មិនដឹងតួនាទីរបស់ខ្លួនឯង[155]។ ដូច្នេះ នាង អ៊ូច បានទទួលស្គាល់ថា គាត់បានទៅធ្វើការនៅតាមតំបន់ភូមិសាស្ត្រជាក់លាក់ ដែលជាកន្លែង អ៊ឹម ចែម បានប្រាប់ DC-Cam ថាគាត់បានធ្វើការជាអនុរបស់នាង។ ការពឹងផ្អែក របស់ សចស លើភស្តុតាងរបស់ នាង អ៊ូច ដើម្បីលើកឡើងថា អ៊ឹម ចែម គ្រាន់តែជាប្រធានសមាគមនារីប្រចាំតំបន់ ១៣ តែប៉ុណ្ណោះនោះ ជាផលវិបាកមានកំហុស ដោយសារភស្តុតាងរបស់គាត់ពិតជាបានគាំទ្រដល់ការបញ្ជាក់ថា អ៊ឹម ចែម គឺជាប្រធានស្រុកកោះអណ្តែត។

66. ទីបី សចស បានច្រានចោល (នៅក្នុងកំណត់សំគាល់ជើងទំព័រមួយ)[156] ភស្តុតាងរបស់ កៅ ឆេង ដែលធ្លាប់ធ្វើការនៅក្នុងស្រុកកោះអណ្តែត ក្នុងឆ្នាំ១៩៧៥ បានប្រាប់ សចស ថា អ៊ឹម ចែម "គ្រប់គ្រងឃោធាស្រុក" នៅកោះអណ្តែត[157]។ សចស បានពិចារណាថា ភស្តុតាងនេះ "ដាច់ឆ្ងាយពីគេ" និងជា "ជាពាក្យចចាមអារ៉ាម"[158]។ ប៉ុន្តែ យើងមើលសម្រាប់បរិបទនេះ និងបន្ថែមលើភស្តុតាងដទៃទៀតដែលសហព្រះរាជអាជ្ញាបានយោង ភស្តុតាងរបស់ កៅ ឆេង បញ្ជាក់អះអាងអំពីមុខតំណែងរបស់ អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែតពិតប្រាកដមែន។

67. ទីបួន សចស ខកខានមិនបានយោងទៅរកភស្តុតាងរបស់ សុខ រុំ ទេ ដែលកម្មករម្នាក់នៅក្នុងស្រុកកោះអណ្តែត ក្នុងឆ្នាំ១៩៧៦ ដែលបានប្រាប់ សចស ថា អ៊ឹម ចែម "គឺជាគណៈស្រុក"[159] និងបានធ្វើការប្រជុំធំៗនៅកោះអណ្តែត "ទាំងប្រុសទាំងស្រី" ដែលអ្នកចូលរួមត្រូវបានគេប្រាប់ឲ្យ "ខិតខំធ្វើការងារ" [...] [អំពី] ការឈ្លានពានពីសំណាក់កងទ័ពវៀតណាម [...] និងនិយាយអំពីការប្រមូលកម្លាំងទាំងអស់ទៅធ្វើការងារតាមសហករណ៍នានា ដើម្បីសម្រេចតាមផែនការឲ្យទាន់

---

154 **D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច, ២៨ មករា ២០១៤, ឆ៤៨។

155 **D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច, ២៨ មករា ២០១៤, ឆ៤៨។

156 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កំណត់សំគាល់ជើងទំព័រ ២៧៥។

157 **D119/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង, ២៨ កុម្ភៈ ២០១៣, ឆ២៤។

158 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កំណត់សំគាល់ជើងទំព័រ ២៧៥។

159 **D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ, ១៩ មីនា ២០១៤, ឆ១០៥។

ពេលវេលា”[160]។ បន្ថែមទៅលើភ័ស្តុតាងរបស់ សុខ រុំ ដែលថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត និងក្រោយមកគាត់បាន “មានឋានៈធំជាង តាញ៉ែន [ដែល ជាប្តីរបស់គាត់ជាលេខាស្រុកអង្គរជ័យ]”[161] នោះ ភ័ស្តុតាងរបស់គាត់អំពីប្រភេទ និងខ្លឹមសារនៃកិច្ចប្រជុំដែលគាត់បានរៀបចំឡើង ធ្វើឲ្យខូចដល់ការសន្និដ្ឋានរបស់ សចស ដែលថាមុខតំណែងតែមួយគត់របស់ អ៊ឹម ចែម គឺគ្រាន់តែជាអ្នកដឹកនាំសមាគមនារីតំបន់១៣[162]។

68. ទីប្រាំ សចស មិនបានយោងទៅរកភ័ស្តុតាងរបស់ រៀល សន ដែលជាអ្នកទទួលខុសត្រូវចំពោះសេដ្ឋកិច្ចនៅក្នុងស្រុកត្រាំកក់ នៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៦ ហើយគាត់បាននិយាយថា អ៊ឹម ចែម “គឺជាគណៈឃុំ ហើយក្រោយមកត្រូវបានតែងតាំងជាគណៈស្រុក”[163]។ ទោះបី រៀល សន មិនដឹងថាស្រុកណាមួយ អ៊ឹម ចែម ធ្វើជាលេខាក៏ដោយ[164] ដោយសារគាត់ធ្វើប្រតិបត្តិការនៅថ្នាក់ស្រុកក្នុងតំបន់១៣ - ភ័ស្តុតាងរបស់គាត់គួរយកមកពិចារណានិងបញ្ជាក់ជាថ្មីថា អ៊ឹម ចែម គឺជាលេខាស្រុកម្នាក់នៅក្នុងតំបន់១៣។

69. ទោះបីជាដីកាដំណោះស្រាយ (សំអាងហេតុ) យោងការអនុមតិរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការប្រើប្រាស់កំណត់ហេតុដោយ នួន ជា សម្រាប់គោលបំណងដោះបន្ទុកនៅពេលធ្វើការវាយតម្លៃជាមួយនឹងភ័ស្តុតាងផ្សេងទៀតនៅលើសំណុំរឿងក៏ដោយ[165]ក៏ សចស ខកខានមិនបានអនុមតិអភិក្រមដូចគ្នានេះចំពោះ អ៊ឹម ចែម នោះដែរ។ ដោយពិចារណាលើការទទួលយករបស់គាត់ និងភ័ស្តុតាងបន្ថែមនៅលើសំណុំរឿង បង្ហាញឲ្យឃើញថា សចស មានកំហុសដែលមិនបានរកឃើញថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត។

## ឧទ្ធរណ៍ទី៦÷ សចស មានកំហុសអង្គហេតុនៅពេលដែលរកឃើញថា អ៊ឹម ចែម មិនមែនជាសមាជិកគណៈតំបន់ ១៣

160 **D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ, ១៩ មីនា ២០១៤, ឆ៤៨។

161 **D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ, ១៩ មីនា ២០១៤, ឆ១០៥។

162 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ១៤៣-១៥០។

163 **D118/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន, ១៨ កុម្ភៈ ២០១៤, *ឆ២២៤ ដែលបានលើកយោងនៅក្នុង* ឯកសារ **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, កថាខណ្ឌ ៥៤។

164 **D118/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន, ១៨ កុម្ភៈ ២០១៤, ឆ២២៤។

165 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ១៣៨។

70. សចស មានកំហុសផ្នែកអង្គហេតុដោយរកឃើញថា អ៊ឹម ចែម មិនមែនជាសមាជិកគណៈតំបន់ ១៣[166]។ សចស ខកខានមិនបានវាយតម្លៃឱ្យបានត្រឹមត្រូវលើភស្តុតាងដែលត្រូវបានពិនិត្យនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) និងបានខកខានមិនបានយោងទៅលើភស្តុតាងពាក់ព័ន្ធផ្សេងៗទៀត។ មិនមានអ្នកវិនិច្ឆ័យអង្គហេតុដ៏សមហេតុផលណាអាចខកខានរកមិនឃើញថា អ៊ឹម ចែម គឺជាសមាជិកគណៈតំបន់ ១៣ នោះទេ ផ្អែកតាមការពិនិត្យដ៏ត្រឹមត្រូវលើភស្តុតាងនេះ។

71. ដីកាដំណោះស្រាយ (សំអាងហេតុ) បានសន្និដ្ឋានបញ្ចប់ទាំងខុសថា មុនតំណែងតែមួយគត់ដែល អ៊ឹម ចែម មាននៅក្នុងភូមិភាគនិរតីគឺជាប្រធានសមាគមនារីតំបន់ ១៣[167]។ វិធីសាស្ត្រដ៏ស្មុកស្មាញចំពោះភស្តុតាងដែលអនុម័តនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ត្រូវបានបង្ហាញតាមរយៈការកត់សម្គាល់របស់ សចស ថា អ៊ឹម ចែម បានសារភាពថា "គាត់ជំនួស តាសោម (ដែលជាលេខស្រុកក្នុងតំបន់ ១៣) មួយរយៈពេលខ្លី នៅពេលគាត់ធ្លាក់ខ្លួនឈឺ"[168]។ សចស មិនមានការយោងបន្ថែមណាទៀតទៅលើការសារភាពដោយ អ៊ឹម ចែម នោះឡើយ ហើយជាចុងក្រោយសន្និដ្ឋានថា គាត់មិនបានមានតួនាទីបែននេះនោះទេ[169]។

72. ជាងនេះទៀត សេចក្តីសង្ខេបរបស់ សចស អំពីបទសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម មានភាពបំភាន់។ អ៊ឹម ចែម បាននិយាយថា "ប្រធានខ្ញុំ ពូសោម គាត់ឈឺទៅ បានគេតំឡើងខ្ញុំប្រគល់ឲ្យខ្ញុំធ្វើ ... (ស្តាប់មិនបាន)។ ប៉ុន្តែខ្ញុំធ្វើនឹង តិចដែរ មួយឆ្នាំអីនឹង តា គាត់ដកឲ្យមកនៅបាត់ដំបង"[170]។ អ៊ឹម ចែម បានរៀបរាប់ការតំឡើងឋានៈនេះក្នុងពាក្យពេចន៍ខាងក្រោមនេះ៖

> អ៊ឹម ចែម៖ អត់ទេ ខ្ញុំធ្វើជំនួសប្រធានខ្ញុំនឹង គ្រាន់ចូលសមាជិក។
> DC-Cam៖ សមាជិកតំបន់?
> អ៊ឹម ចែម៖ ចា៎![171]

---

166 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ១៤៤។

167 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៣។

168 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៤៧។

169 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៨។

170 **D123/1/5.1c** បទសម្ភាសន៍ អ៊ឹម ចែម ដោយ DC-Cam , ៦ មេសា ២០១២, EN 00951849។

171 **D123/1/5.1c** បទសម្ភាសន៍ អ៊ឹម ចែម ដោយ DC-Cam, ៦ មេសា ២០១២, EN 00951849។

73. ដូច្នេះ អ៊ឹម ចែម បានទទួលស្គាល់ថា ត្រូវបានតំឡើងឋានៈជាសមាជិកគណៈតំបន់ ១៣ និងថា គាត់បានកាត់តំណែងនេះរយៈពេលមួយឆ្នាំ មុនពេលត្រូវផ្ទេរទៅភូមិភាគពាយ័ព្យ ដែលដូច សចស បានរកឃើញនៅត្រង់ចំណុចផ្សេងទៀតក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) គឺនៅពេលដែលគាត់បានដឹកនាំការបោសសម្អាត[172]។ ប៉ុន្តែ យ៉ាងចម្លែកនោះ សចស បានទាត់ចោលភ័ស្តុតាងនេះដោយមិនមានការពិភាក្សាបន្ថែមទៀតឡើយ។

74. នៅលើកំហុសនេះ សចស បានខកខានមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវលើភ័ស្តុតាងរបស់សាក្សីជាច្រើន ដែលបញ្ជាក់អំពីតួនាទីរបស់ អ៊ឹម ចែម នៅក្នុងគណៈតំបន់ ១៣។ សចស មិនបានរាប់បញ្ចូលចម្លើយទាំងអស់នេះដោយផ្អែកលើមូលដ្ឋានដែលថា សាក្សីទាំងអស់នេះផ្តល់ភ័ស្តុតាង "មានភាពច្បាស់លាស់ និងជឿជាក់ដែលមានកម្រិត" អំពីតួនាទីរបស់ អ៊ឹម ចែម[173]។ ប៉ុន្តែ សាក្សីទាំងនេះមានភាពជាក់លាក់ និងច្បាស់លាស់ថា អ៊ឹម ចែម មានតួនាទីក្នុងគណៈតំបន់ ១៣ ក្រៅពីតួនាទីជាប្រធានសមាគននារីតំបន់ ១៣។ សាក្សី សួន មុត ជាកម្មាភិបាលភូមិភាគនិរតីដែលត្រូវបានផ្ទេរទៅកាន់ភូមិភាគពាយ័ព្យជាមួយកងកម្លាំងបោសសម្អាតរបស់ អ៊ឹម ចែម នោះ បាននិយាយថា "តាមខ្ញុំដឹង យាយ ចែម ជាសមាជិកគណៈតំបន់ ១៣ ក្នុងខេត្តតាកែវ។ [...] ខ្ញុំបានស្គាល់ និងឃើញគាត់ ដោយសារគាត់បានមកដឹកនាំអង្គប្រជុំ និងមកធ្វើការនៅកន្លែងដែលខ្ញុំរស់នៅ"[174]។ សួន មុត បានបន្ថែមទៀតថា ក្នុងឋានៈជាសមាជិកគណៈតំបន់ ១៣ អ៊ឹម ចែម គ្រប់គ្រងជាច្រើនលើ "ផ្នែកតូចៗដែលស្ថិតនៅក្រោមតំបន់។ ឧទាហរណ៍ដូចជា សាខាលើកទំនប់ ជីកប្រឡាយ និងសេដ្ឋកិច្ច។ល។"[175]។ សាក្សី អ៊ុល ហឿន ដែលបានធ្វើការនៅស្រុកត្រាំកក់ បានប្រាប់ សចស ថា "យាយចែម គឺជាមនុស្សថ្នាក់ទី៣ នៅក្នុងតំបន់១៣ [...]។ តាសោម គឺជាមនុស្សទី១ និងតាមុត គឺជាមនុស្សទី២ ចំណែកតាគារ គឺមនុស្សទី៣។ ក្រោយពី តាគារ ត្រូវបានដកចេញឲ្យទៅធ្វើការនៅកន្លែងរ៉ែថ្ម នៅភ្នំជ្រៃអូរញ៉ៅ គឺយាយចែម បានឡើងជំនួសតួនាទី តាគារ"[176]។ បន្ថែមលើនេះទៀត សាក្សី អន សុភាព ដែលជាយុវជន បកក បានប្រាប់ សចស ថា "ខ្ញុំដឹងថា អ៊ឹម ចែម ជាគណៈតំបន់១៣ ដោយសារតែខ្ញុំបានឃើញរូបថតគាត់នៅក្នុងទស្សនាវដ្តីក្នុងរបបខ្មែរក្រហម។

172 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥២។

173 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៨។

174 **D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត, ១៦ តុលា ២០១៤, ឆ.១៧-១៨។

175 **D219/37** កំណត់ហេតុស្តាប់ចម្លើយ សួន មុត, ១៦ តុលា ២០១៤, ឆ.២៥។

176 **D193/8.2** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន, ១៣ តុលា ២០១៤, ឆ.១០។

រូបថតគាត់កាលណោះ គឺ ស្លៀកពាក់អាវខ្មៅ ខោខ្មៅធម្មតា ឈរម្នាក់ឯង ហើយគេសរសេរថា "អ៊ឹម ចែម ជាគណៈតំបន់១៣""[177]។

75. សចស ផ្តោតលើភ័ស្តុតាងដែលគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនថា អ៊ឹម ចែម ជាប្រធានសមាគននារីតំបន់១៣ ហើយបានខកខានមិនបានពិចារណាថា ភ័ស្តុតាងនោះអាចគ្រាន់តែធ្វើឲ្យត្រូវគ្នាជាមួយនឹងអង្គហេតុដែលថា រូបគាត់គឺជាសមាជិកគណៈតំបន់ ១៣ នាពេលនោះតែប៉ុណ្ណោះ។ ភ័ស្តុតាងបង្ហាញថា អ៊ឹម ចែម បានកាន់មុខតំណែងទាំងពីរនេះក្នុងតំបន់បន្តកន្ទុយគ្នា។ ឧទាហរណ៍ សាក្សី មូល អេង ដែលជាលេខាស្រុកបវេល ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បាននិយាយយ៉ាងច្បាស់ថា "យាយចែម មានតួនាទី២។ គាត់ជាគណៈតំបន់១៣ ជាមួយ តាសោម ផង ហើយគាត់ជាគណៈនារីដឹកនាំតំបន់ ១៣ ផង"[178]។ សាក្សី ម៉ឹង វេត ដែលបានធ្វើការនៅក្នុងមន្ទីរ១៦០ ក្នុងតំបន់១៣ បានប្រាប់ សចស ថា "តួនាទី យាយចែម គឺជាអនុម្នាក់នៅក្នុងគណៈតំបន់ ១៣ ទទួលខុសត្រូវនារីនៅក្នុងតំបន់។ យើងអាចនិយាយបានថា គាត់ជាសមាជិកអចិន្ត្រៃយ៍តំបន់១៣"[179]។ ម៉ឹង វេត បានប្រាប់ សចស ផងដែរថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំតំបន់១៣ ហើយ "បានឃើញនៅលើខ្នងសំបុត្រ ដែល តាសោម ផ្ញើសំបុត្រទៅយាយ ចែម ដោយចារលើខ្នងសំបុត្រថា "ជូន*មិត្ត*នារី ចែម គណៈអចិន្ត្រៃយ៍តំបន់១៣"[180]។ លើសនេះទៀត សាក្សី ពេជ្រ ជឹម ដែលជាអនុលេខាស្រុកត្រាំកក់ បានប្រាប់ សចស ថា គេគិតថា អ៊ឹម ចែម "ជាគណៈតំបន់ទទួលខុសត្រូវខាងនារីផងដែរ ព្រោះគាត់តែងតែចុះទៅធ្វើការតាមស្រុកទាំងអស់ក្នុងតំបន១៣"[181]។

76. សចស យោងលើភ័ស្តុតាងរបស់ ប៊ុន ធឿន ដែលជាសមាជិកគណៈឃុំសន្លុង ជាសញ្ញាណនៃសាក្សីនានាដែលបានផ្តល់ព័ត៌មានជាក់លាក់ជាងគេ អំពីតួនាទីរបស់ អ៊ឹម ចែម ជាប្រធានសមាគមនារីប្រចាំតំបន់ ១៣ ជាជាងតួនាទីនៅក្នុងគណៈតំបន់១៣[182]។ ទោះជាយ៉ាងណាសាក្សី ប៊ុន ធឿន បានប្រាប់ សចស ថា *បន្ថែមលើ* តួនាទីជា "ប្រធានសមាគមនារីរបស់តំបន់ ១៣"[183] អ៊ឹម ចែម

---

177 **D118/78** កំណត់ហេតុស្តាប់ចម្លើយ អន សុភាព, ២៥ មិថុនា ២០១៣, ឆ.៨។

178 **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង, ៤ ឧសភា ២០១៥, ឆ.១៤៣។

179 **D119/83** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត, ១០ កុម្ភៈ ២០១៤, ឆ.១៨។

180 **D119/84** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត, ១១ កុម្ភៈ ២០១៤, ឆ.២០។

181 **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម, ១៩ មិថុនា ២០១៤, ឆ.៤០ (គូសបញ្ជាក់បន្ថែម)។

182 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៤៨, ជើងទំព័រ២៧១។

183 **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន, ១០ កក្កដា ២០១៤, ឆ.២៨។

"ក្លាយជាសមាជិកតំបន់១៣"[184]។ ប៊ុន ធឿន ផ្អែកលើការណ៍ដែលថា អ៊ឹម ចែម នៅ "ថ្នាក់លើ"[185] និង "វត្តមានរបស់គាត់គ្រប់ការប្រជុំតំបន់"[186]។

77. សចស បានកំណត់លក្ខណៈខុសអំពីភស្តុតាងពាក់ព័ន្ធផ្សេងទៀត ដោយគ្រាន់តែបង្ហាញថា "ការទទួលខុសត្រូវរបស់គាត់ [អ៊ឹម ចែម] រួមមាន ការចាត់តាំងមនុស្សឲ្យធ្វើការងារ និងទៅកន្លែងផ្សេងៗ"[187]។ សចស មិនដែលពន្យល់ការយល់ឃើញរបស់ខ្លួនអំពីរបៀបដែលការងារចាត់តាំងផ្សេងៗ និងខុសៗគ្នាទាំងឡាយដែលពួកគេបានសំដៅលើ ថាស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ អ៊ឹម ចែម នោះ គឺគ្របដណ្តប់តែក្រោមតួនាទីជាប្រធានសមាគមនារីប៉ុណ្ណោះ។ កំហុសនៅក្នុងសនិទានភាពរបស់ សចស នេះ ត្រូវបានបង្ហាញដោយភស្តុតាងរបស់ អ៊ឹង ជឿន ជាកម្មាភិបាលភូមិភាគនិរតី ដែលបានប្រាប់ សចស ថា "ខ្ញុំបានជួប យាយចែម នៅពេលដែលគាត់បានកោះហៅប្រធានភូមិគ្រប់ភូមិមកចូលរួមប្រជុំ។ ជួនកាលនៅក្នុងអង្គប្រជុំគាត់និយាយថាគាត់ទើបតែមកពីស្រុកនេះ ស្រុកនោះ ដូចជាស្រុកត្រាំកក់ជាដើម។ ដូច្នេះ ហើយបានជាខ្ញុំដឹងថា គាត់បានទៅធ្វើការនៅតាមស្រុកផ្សេងៗនៅក្នុងតំបន់"[188]។ សាក្សី ខឹម បឿន ជាប្រធានឃុំជាងទង ក្នុងស្រុកត្រាំកក់ ក៏បានប្រាប់ សចស ថា អ៊ឹម ចែម បាននិយាយអំពី "បញ្ហាសន្តិសុខ ឬការចាប់ខ្លួនមនុស្ស ឬខ្មាំង ឬជនក្បត់ ឬការបោសម្អាត" នៅពេលប្រជុំតំបន់១៣[189]។ ចម្លើយទាំងអស់នេះគឺពិតជាខុសគ្នាខ្លាំងពីការសន្និដ្ឋានរបស់ សចស ថា អ៊ឹម ចែម បានចូលរួមការប្រជុំនានាដោយសំអាងលើមូលដ្ឋានថាជាប្រធានសមាគមនារីតំបន់១៣។ មិនមានត្រង់ណាទាល់តែសោះនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ដែល សចស ពន្យល់អំពីរបៀបដែលកម្រិតសិទ្ធិអំណាច អ៊ឹម ចែម មានអាចកើតចេញតែពីតួនាទីរបស់គាត់ជាប្រធានសមាគមនារីនោះ។

---

184 **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន, ១០ កក្កដា ២០១៤, ឆ.២៩។

185 **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន, ១០ កក្កដា ២០១៤, ឆ.៥៥។

186 **D118/274** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន, ១០ កក្កដា ២០១៤, ឆ.២៩។ *សូមមើលផងដែរ* ឆ.៧២។

187 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១៤៨។

188 **D119/156** កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ជឿន, ៤ កញ្ញា ២០០៤, ឆ.១៧។

189 **D118/242** កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន, ២១ ឧសភា ២០១៤, ឆ.៩៩។

78. លើសនេះទៀត សចស បានខកខានមិនបានពិចារណាលើភ័ស្តុតាងដ៏ច្បាស់លាស់ និងពាក់ព័ន្ធ ដែលបានបង្ហាញថា អ៊ឹម ចែម បានកាត់មុខតំណែងក្នុងគណៈតំបន់១៣[190]។ ឧទាហរណ៍ សាក្សី មូល អេង ដែលជាលេខាស្រុកបរេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានថ្លែងថា "ខ្ញុំគ្រាន់តែ ដឹងថា យាយចែម មកពីតាកែវ ហើយគាត់ជាប់ជាសមាជិកតំបន់ ១៣ ហើយ"[191]។ មូល អេង បានរៀបរាប់លម្អិតអំពីរបៀបដែល "គេប្រកាសក្នុងវិទ្យុថា យាយ ចែម ជាតំណាងរាស្ត្រ នៅខេត្តតាកែវ។ ហើយយោធាដែលធ្លាប់ស្គាល់គាត់ក៏និយាយថាគាត់ សមាជិកគណៈតំបន់១៣ ដែរ "[192]។ មូល អេង បាននិយាយថា "ឮទូទៅហើយថា យាយចែម ជាសមាជិកគណៈតំបន់១៣"[193]។ សាក្សី ខឹម វ៉ៃ ដែលជានិរសារតំបន់ក្នុងខេត្តតាកែវ ហើយដូច្នេះស្ថិតក្នុងមុខតំណែងមួយដឹងអំពី រចនាសម្ព័ន្ធដឹកនាំនេះ បានថ្លែងថា "តាទិត្យ និងយាយចែម នៅគណៈតំបន់១៣"[194]។ បន្ថែមលើ នេះទៀត សាក្សី សុខ រុំ ដែលបានធ្វើការនៅកោះអណ្តែត បានប្រាប់ សចស ថា "យាយាចែម គឺជា គណៈតំបន់១៣។ យាយចែម ទទួលខុសត្រូវកងកុមារ កងនារី និងកងយុវជន នៅក្នុងតំបន់ ១៣"[195]។ ចម្លើយទាំងអស់នេះពិតជាគាំទ្រដល់ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាយ៉ាងច្បាស់ ក្រឡែត ប៉ុន្តែមិនត្រូវបានលើកឡើងដោយ សចស ឡើយ។

79. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ក៏បានយោងសំដៅលើ អ៊ឹម ចែម ថាមានតួនាទីនៅក្នុងគណៈតំបន់១៣ ផងដែរ[196] ដោយរួមមាន ធង ភួន ដែល "បានជួបផ្ទាល់ ជាមួយពួកគេនៅការដ្ឋានលើកទំនប់ ដឹកប្រឡាយ ឈ្មោះ យាយអ៊ិន ចែម គាត់ជាគណៈតំបន់ ១៣"[197]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយនេះមិនត្រូវបានពិចារណានៅក្នុង

---

190 ខណៈដែលចម្លើយរបស់សាក្សីអាចត្រូវបានយោងសំអាងនៅក្នុងផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយនោះ ពួកគេមិនត្រូវបានពិនិត្យឡើងវិញសម្រាប់បញ្ហាទាក់ទងនឹងតួនាទីរបស់ អ៊ឹម ចែម ក្នុងគណៈតំបន់ ១៣ ទេ។

191 **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង, ៤ ឧសភា ២០១៥, ឆ.១២៧។

192 **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង, ៤ ឧសភា ២០១៥, ឆ.១៣០។

193 **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង, ៤ ឧសភា ២០១៥, ឆ.១៤០។

194 **D219/636** កំណត់ហេតុស្តាប់ចម្លើយ ខឹម វ៉ៃ, ២១ ធ្នូ ២០១៥, ឆ.៣៨។

195 **D119/108** កំណត់ហេតុស្តាប់ចម្លើយ សុខ រុំ, ១៩ មីនា ២០១៤, ឆ.៤៥។

196 *សូមមើល*, **D5/1133** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែម ជ្រន, ១ តុលា ២០១២, EN 01144435; **D5/1303** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សាមី, ៨ វិច្ឆិកា ២០១៣, EN 01191036; **D5/1615** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភ្លី លី, ១៣ សីហា ២០១៣, EN 01168228។

197 **D5/1304** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធង ភួន, ៨ មេសា ២០១៣, EN 01144492។

ដីកាដំណោះស្រាយ (សំអាងហេតុ) ឡើយ បើទោះបីជា សចស ដឹងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានព័ត៌មានពីបទពិសោធន៍ផ្ទាល់ខ្លួន ដែលពាក់ព័ន្ធទៅនឹងការបង្ហាញអង្គហេតុពាក់ព័ន្ធក៏ដោយ[198]។

80. ការសន្និដ្ឋានរបស់ សចស ថា ការទទួលខុសត្រូវជាច្រើនរបស់ អ៊ឹម ចែម នៅថ្នាក់តំបន់ ១៣ អាចបានមកតែពីតួនាទីរបស់គាត់ជាប្រធានសមាគមនារីនោះ គឺមិនមានការគាំទ្រដោយភស្តុតាងនោះទេ។ ខណៈដែលសាក្សីមួយចំនួនប្រហែលជាបាននិយាយថា អ៊ឹម ចែម គឺជាសមាជិក ឬជាអនុលេខតំបន់១៣ នោះ ជារួមនៅទូទាំងកំណត់ហេតុនៃការស្តាប់ចម្លើយ បង្ហាញថា អ៊ឹម ចែម ស្ថិតនៅក្នុងគណៈតំបន់១៣ ដាច់ដោយឡែកពីតួនាទីរបស់គាត់ជាប្រធានសមាគមនារី។

81. ការខកខានរបស់ សចស ក្នុងការបង្ហាញថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត និងជាសមាជិកគណៈតំបន់១៣ បង្ហាញឲ្យឃើញថាវាជាមូលហេតុដែលដីកាដំណោះស្រាយ មិនលើកយកការចោទប្រកាន់ទាំងឡាយរបស់សហព្រះរាជអាជ្ញា ដែលថា អ៊ឹម ចែម បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម (JCE) នៅភូមិភាគនិរតី។ ហេតុដូច្នេះ ការច្រានចោលកំហុសអង្គហេតុទាំងអស់នេះ តម្រូវឲ្យមានការវាយតម្លៃថ្មីៗលើការទទួលខុសត្រូវរបស់ អ៊ឹម ចែម ក្រោមទម្រង់ JCE ចំពោះឧក្រិដ្ឋកម្មនានានៅក្នុងភូមិភាគនិរតី។

## V. ដំណោះស្រាយដែលស្នើសុំ

82. អាស្រ័យមូលហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យ អបជ កែប្រែកំហុសអង្គច្បាប់ និងអង្គហេតុដូចមានចែងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ និងសូមឲ្យអនុវត្តចំណុចណាមួយដូចខាងក្រោម៖

(១) បញ្ជូនសំណុំរឿងនេះត្រឡប់ទៅ សចស វិញ ដោយណែនាំឲ្យ សចស ធ្វើការវាយតម្លៃឡើងវិញ ថាតើ អ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ឬយ៉ាងណា ឬក៏ជម្រើសម្យ៉ាងទៀត

---

198 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១០៧។

(២) អបជ ខ្លួនឯងផ្ទាល់ធ្វើការវាយតម្លៃរឿងក្តីនេះឡើងវិញ ដោយពិចារណាលើកំហុសអង្គច្បាប់ និងអង្គហេតុទាំងអស់ដែលមានរៀបរាប់ខាងក្នុងបណ្តឹងឧទ្ធរណ៍នេះ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |